# ផ្កាយចរប្រចាំអាយុ

លោកអ្នកនាងចង់ជ្រាបពីធាតុពិតរបស់ខ្លួន ឬអ្នកដទៃដោយត្រូវការអង្កេតមើលតម្រានេះ ពីករណីជាចាំបាច់នឹងកើតមានក្នុងទីចំពោះនាបច្ចុប្បន្នជាយ៉ាងណា។ ។

នោះសូមជ្រាបជាមុននូវអាយុពេញ ក្នុងទីនេះ សំដៅយកអាយុដែលឆ្នាំពេញ ១២ខែជាកំណត់ ឆ្នាំមិនគ្រប់១២ខែ លើកទុកមិនយកជាការទំនាយនោះឡើយ ។

ឧទាហរណ៍ : នាយ ធ កើតឆ្នាំមមី គ.ស.១៩៥៤ មើលក្នុងឆ្នាំមមី គ.ស.១៩៦៧ បើគិតជាឆ្នាំបាន១៣ឆ្នាំ តែដោយអំណាចខែមិនគ្រប់១២ខែនៃឆ្នាំមមី ទើបលើកឆ្នាំនេះត្រូវគិតជាបានការតែត្រឹម១២ឆ្នាំពេញ សូមចាំថាបើអាយុលោកអ្នកនាងរាប់បាន១៣ឆ្នាំ ចូរដកមួយឆ្នាំចេញជាដរាបទោះមានចំនួនប៉ុន្មានក៏ដោយ ឯចារិកលក្ខណៈចំនួនក្នុងតម្រាមិនបានបន្ថយឡើយ ។

ដូច្នេះនាយ ធ រាប់អាយុពេញបាន១២ឆ្នាំ មើលខ្ទង់ចំនួន១២ សូមយកតាតម្រានេះឱ្យបានគ្រប់ៗគ្នាទៅមើលមាន ប្រសិទ្ធភាពជាប្រត្យក្ស បើកាលណាមិនបានយកតាមតម្រានេហទេ មុខជាមានការខុសភ្លាត់ប្រាសចាកពិតជាមិនខាន ។

**រូបភាព ទំព័រ ៨៩**

បុរសអាយុ ១២, ២០,២៨,៣៦,៤៤,៥២, និង ៦០ឆ្នាំ ។

ស្រីក្នុងអាយុ ១៦,២៤,៣២,៤០,៤៨,៥៦ និង ៦៤ ឆ្នាំ ។

លោកអ្នកនាង កាលមានអាយុប៉ុណ្ណេះ មានព្រឹត្តិការណ៍កើតឡើងចំពោះយុវជន-យុវតី នៅរយៈខែមេសា ១, ឧសភា១ សឹងបានសាន្តសុខប្រកបទៅដោយសេចក្ដីរីករាយចិត្តច្រើនប្រការ បើក្នុងកិច្ចការសិក្សា មុខជាបានកើនសតិបញ្ញា យល់សេចក្ដីចងចាំមេរៀនយ៉ាងហ្មត់ចត់ ។

ចំពោះសេចក្ដីស្នេហ៍ ត្រូវបានជួបអារម្មណ៍ល្អជាមួយភេទផ្ទុយគ្នា ដោយច្រើនខុសគ្នាទៅដោយជាតិសាសន៍មកប្រតិស្ឋចងមេត្រីជាមួយតែមិនបានជាស្ថាពរទេ ។

ចំពោះកិច្ចការទូទៅ អាចឱ្យកាត់កត់សម្គាល់បាន បើលោកអ្នកនាងមានបំណងចង់ទៅប្រកបកិច្ចការអាជីវកម្មគួរសំដៅទៅខាងទិសនិរតីចុះ សេចក្ដីបំណងមុខជាចេញទ្រង់ទ្រាយធំ ឱ្យភេទចំឡែកគួរឱ្យចាប់អារម្មណ៍ជាមិនខាន ថាបើ ការនោះជាចាំបាច់គប្បីប្រញាប់ទៅឱ្យបានទាន់កាលៈទេសៈនេះឯង ។

ចំពោះគូស្នេហ៍ បើឱកាសហុចឱ្យហើយក្នុងរយៈពេលនេះបើចង់រៀបអាពាហ៍ពិពាហ៍បើជាគិតលៃពន្យារពេលបាន គួរតែរំកិលពេលទុកឱកាសបន្តិចទៅទៀត មិនគួររៀបចំទាំងបង្ខំឡើយ សូមគិតអានរឿងនេះឱ្យបានដិតដល់បន្តិច ។

ចំពោះលាភផល បើភ័យផលដុះដាលឡើងមកខាងទិសទីភាគខាងនិរតី សូមទទួលដោយរីករាយចុះ ព្រោះថានាទីនេះជាផលល្អមានដល់លោកអ្នកនាងស្របតាមទិសទេពារ័ក្ខហើយ ចំពោះហេតុការណ៍ បើលោកអ្នកនាងជាប់ទាក់ទងកិច្ចកង្វល់ពីពេលមុន ហើយការណ៍នោះគឺស្ងប់បាត់សូន្យ លុះតែដល់រយៈនេះស្រាប់តែមានលេចឮពាក្យចចាមអារាមពីខាង

ទិសនិរតីមក បើយ៉ាងនេះ សូមលោកអ្នកយល់ចុះថា មិនជាហេតុនាំមកសេចក្តីទុក្ខឬអន្តរាយដល់ខ្លួនទេ ការណ៍នោះគ្រាន់តែជន្លឺបជនរតែប៉ុណ្ណោះ ។

លោកអ្នកលាភជោគដែលជាចំណោទចោទចំជាងគេ ក្នុងរយៈខែទាំង២នេះនាពេលអាយុប៉ុណ្ណេះដោយច្រើន១ជាលាភសត្វជើងពីរហើយ មានគេហួងហែងថែរក្សាជានិច្ច ប្រសិនលោកអ្នកបានជួបប្រទះក្នុងខណៈនេះ មិនគួរសម្រេចចិត្តជាឯកច្ឆន្ទឡើយ គប្បីពិចារណាឱ្យបានជុំវិញបន្តិច ។

នៅរយៈខែមិថុនា និង កក្កដា ២ខែនេះ សូមប្រយ័ត្នការ ។

ចំពោះរឿងហេតុ នឹងមានសេចក្តីស្មុះស្មាប់រំខានបន្តិចម្តង១កើតឡើង ពុំនោះមានការនឿយណាយលះបង់ការព្យាយាមដោយគំនិតបាញ់ឆ្ពោះទៅរកទិសដៅផ្សេងទៅវិញ ។ ចំពោះការងារ មធ្យោបាយដែលបានមកប្រកបអំពីមុននៅរយៈ ពេលនេះអាចបណ្តាលឱ្យយោលចិត្តឃ្លាតចាកពីគម្រោងការដែលគិតទុក បើមិនច្រើនក៏តិច អាស្រ័យហេតុលង់គំនិតខ្លះដោយមាតុគ្រាមតាមការពិតមេរោគដែលផ្តើមឡើងគួរប្រយ័ត្នមនុស្សផ្ទុយភេទចូលមកស្នាក់នៅរួមបន្ទុក រឿងនេះជារឿង វែងឆ្ងាយហើយបង្កបង្កើតជាអង្គការក្តៅក្រហាយនាំរលាយសេចក្តីចំរើនគ្រប់បែបយ៉ាង ។

មនុស្សផ្ទុយភេទស្រលាញ់ជាអាសន្នធំ សត្រូវជិតឆ្ងាយចាំថ្កោលទោសទាញយកផលប្រយោជន៍ក្នុងរឿងនេះមិន ខានព្រោះម្ចាស់ខ្លួនលង់លក់នៅក្នុងអបាយមុខគួរឱ្យស្តាយ តែកុំអាលអស់សង្ឃឹម គង់មានឱកាសខ្លះទៀតឆ្លៀតផ្តល់សេចក្តីរីករាយឱ្យវិញជាមិនខាន ។

ខែសីហា និង កញ្ញា ទាំង២ខែនេះ លោកអ្នកនាងមានជន្មាយុកម្រិតប៉ុណ្ណេះ មុខជាមានការរីកសាយទៅដោយកិត្តិ យសព្រមទាំងសតិបញ្ញាការសិក្សានឹងបានយល់សេចក្តីចងចាំល្អនៅគតិការសិក្សា ប្រសិនបើការដល់គូប្រឡងប្រជែងក្នុង វវាងខែនេះមុខតែមានសង្ឃឹមថានឹងបានជាប់ពិន្ទុតាមគួរដល់កិច្ចការដែលត្រូវធ្វើនោះឯង ។

ចំពោះសេចក្តីប្រព្រឹត្តិ : ក្នុងកាលណាក៏មិនដូចពេលនេះ សេចក្តីព្យាយាមចេះតែមានសន្ទុះជឿនលឿនគ្រប់ពេលវេលាកិរិយាប្រព្រឹត្តហាក់ដូចជាមានពន្លឺឆ្លុះយល់ប្រាកដជាផ្ទត់គំនិតគិតឃើញខុសត្រូវ ល្អ អាក្រក់ ផ្សេង១ ចេះបំបែកចិត្តចេញពីការឥតប្រយោជន៍ ហើយផ្តើមគំនិតឈមស្មោះទៅរកផ្លូវសំខាន់១ ។

ចំពោះសេចក្តីស្នេហ៍ : បើលោកអ្នកនាងសំភីចិត្តទៅខាងផ្លូវស្នេហានោះ ជាការងាយជួបប្រទះណាស់ ព្រោះថារឿងនេះផ្កាយចររបស់អស់លោកអ្នកចង្អុលនាទីប្រាប់ថា ត្រូវទៅជួបជូននឹងគូស្នេហាដែលជាការសប្បាយ តែគូស្នេហ៍ដែល មានមកក្នុងពេលនេះជាគូគាប់ផ្លូវចិត្ត ហើយគូនោះមានឋានៈលើសខ្ពះគ្នាដូចមេឃនិងដី ប្រសិនបើសង្កេតឱ្យហ្មត់ចត់គួរតែកុំសម្រេចចិត្តសិន ចូររង់ចាំដាច់ខែនេះឬឆ្នាំនេះទៅបានសម្រេចជាស្ថាពរ តាមការសន្និដ្ឋានថាគូរបស់អស់លោក អ្នក ក្នុងទីនេះគឺជាកម្មទេ ខាងមុខនឹងបណ្តាលឱ្យមានហេតុវិបត្តិផ្សេង១ មានការក្តៅក្រហាយជាដើម ។

ខែតុលានិងវិច្ឆិកា ក្នុងវវាង២ខែនេះ បានលទ្ធផលជាប់ប្រសើរ គឺសម្រេចតាមគោលដៅ ជាពិសេសសេចក្តីដែលខ្លួនប្រព្រឹត្តនិងការដែលមាននៅជុំវិញខ្លួន ផលដែលកើតមានក្នុងរយៈពេលនេះអាចកត់សម្គាល់យ៉ាងធ្ងន់ធ្ងរជាងគេនៅត្រង់សេចក្តីផ្គូរផ្គងរកគូស្រករ លាភបានពីមនុស្សផ្ទុយភេទ ឬបរសាសន៍ កិច្ចការដែលសន្និដ្ឋានថាល្អបានមកពីនីរតីទិស ។

ខែធ្នូ និង ខែមករា នៅក្នុងរវាងខែ២នេះ សេចក្តីទុកវំខាន ការក្តៅក្រហាយចេះតែផុសផុលឡើងបន្តិចៗរឿយៗ ហើយជាពិសេសក្នុងបន្ទុកគ្រួសារ ។

ចំពោះការសិក្សា: លោកអ្នកនាងគួរតាំងស្មារតីឱ្យរឹងប៉ឹងចាំយមមុខតទល់នឹងការកង្វល់តូច-ធំក្នុងពេលនេះ គឺថាសេចក្តីសម្រេចចិត្តក្នុងផ្លូវសិក្សាទាំងប៉ុន្មានត្រូវរង្គោះរង្គើ សឹងតែអស់សង្ឃឹម ។

ចំពោះអាជីវកម្ម : ផ្នែកខាងរបរការប្រកបអាជីព មុខតែជួបប្រទះនិងឧបសគ្គពុំខាន បើការនោះជាប់ទាក់ទងនឹងផ្លូវឆ្ងាយដាច់ស្រយាល មុខតែខកដំណើរត្រឹមហ្នឹងហើយ បើការនោះមានសង្ឃឹមយ៉ាងមាំ ក៏គប្បីលែងទុកចិត្តទៅ ។

ចំពោះលាភផល : សត្រូវមានមកពីទិសនិរតី ប្រាកដជាសត្រូវធំ ទ្រព្យសម្បត្តិដែលចេញផុតពីដៃ ទោះក្នុងសភាពណាក៏ដោយ មិនអាចបានកម្រៃផលវិញឡើយ ការងារដែលសង្ឃឹមផល ក៏មុខតែអសារឥតការទាំងអស់ ហេតុនេះត្រូវប្រយ័ត្នខ្លួនក្នុង២ខែនេះឱ្យហ្មត់ចត់ចុះ ។

ខែកុម្ភៈ និង មីនា លោកអ្នកមានអាយុត្រឹមប៉ុណ្ណេះ ពេលនេះត្រូវព្យុះសង្ឃរាបក់បោកខ្លាំងហើយ ព្រោះថាក្នុង១០ខែខាងដើមមានល្អ មានអាក្រក់លាយឡំគ្នា នៅ២ខែខាងចុងនេះជាដំណាក់ចុងក្រោយបង្អស់ បើលោកអ្នកធ្វើការប្រយ័ត្នមិនដិតដល់ទេ នោះមុខតែមានវិបត្តិយ៉ាងធ្ងន់ ដូចជាវេរាពណ៍ត្រូវបរាជ័យលាយលង្កា ។

ចំពោះការងារ : បើធ្វើការរាជការនឹងមានសត្រូវប្រមាថ បៀតបៀនឱ្យឃ្លាតចាកពីទីកន្លែង ពុំនោះមានហេតុផលជាទុក្ខទោសបណ្តាលមកពីមនុស្សភេទផ្ទុយគ្នា ធ្វើឱ្យបែកបាក់ធ្លាក់ចិត្តអស់សង្ឃឹម បើប្រកបកិច្ចការជាពាណិជ្ជកម្មវិញ ក្នុងពេលនេះបើលោកអ្នកធ្លាក់ជោគមុខតែងបង់ខាតយ៉ាងធំ សឹងតែរលីងលោះទ្រព្យថ្មីចាស់រលីសធេង ។

ចំពោះកិច្ចការប្រតិបត្តិការ : ក្នុងទីនេះកុំបង្ខំហួសព្រំដែន បច្ចាមិត្តរបស់ខ្លួនវាបានយល់កិច្ចការអស់ហើយ បើយកសមគួរត្រូវតែផ្លាស់អាកប្បកិរិយាទើបប្រព្រឹត្តបាន ។

ចំពោះគូគ្រង : គ្រួសារក្នុងបន្ទុកមានការទ្រាញ់ធុញថប់ចំពោះរូបអស់លោកអ្នកហើយ បើពុំនោះមានការប្រឆាំងតបវិញខ្វះការគិតពិចារណា បើហោចណាស់ក៏ពេលអ្វីពីរឿងអ្វីមួយនាំឱ្យអផ្សុកត្រចៀកនឹងចិត្តដែរ ។

ចំពោះរោគាពាធ : បើចាប់ជំងឺឈឺមេមម្តាយ វង្វេងស្មារតី ក្តៅណាស់ មិនស្រេកឃ្លានចំណីឡើយ បើរៀបចំសែនគប្បីរៀបពៃព្យូត កន្ទោង៤ បាយស-ក្រហមញាំភ្លា ប័នរូបយក្ខកាន់ដំបង១ រូបបិសាច ៧នាក់ រូបអ្នកជំងឺ១ រៀបដាក់ពៃ តាមសមគួរសែនហើយយកពៃទៅទុកនាទិស“និរតី” បានជាសមបំណង ។

.................................

## រូបភាពទំព័រ ( ៩៦)

ប្រុសអាយុ ១៣,២១,២៩,៣៧,៤៥,៥៣ និង ៦១ ឆ្នាំ ។

ស្រីអាយុ ១៧,២៥,៣៣,៤១,៤៩ និង ៥៧ ឆ្នាំ ។

ប្រុស-ស្រីមានអាយុចរចូលដល់កម្រិតនេះ មានហេតុផលដល់ខ្លួនលោកអ្នកនាង តាមព្រឹត្តិការណ៍ដូចតទៅនេះ :

ចំពោះការសិក្សា : បើឱកាសគួរដល់កាលៈទេសៈប្រឡងប្រជែង អាចឱ្យសន្និដ្ឋានបានថា បានជាប់ជាស្ថាពរ តាមគួរដល់ថ្នាក់និងកិច្ចការត្រូវជ្រើសរើស ប្រសិនបើមិនដូច្នោះទេ មុខជាបានចំរើនសតិបញ្ញាតម្រិះវិជ្ជាល្អួតលាស់ អាចយល់សេចក្តីល្អិតល្អន់បាន នៅក្នុងថ្នាក់គួរឱ្យសរសើរដល់សិស្សានុសិស្សទាំងពួង ។

ចំពោះគូគ្រង : ក្នុងខែមេសា និង ឧសភា លោកអ្នកនាងមិនទាន់មានគូប្រចាំជីវិតនៅឡើយ មុខតែមានដឹងពីហេតុផលពីគូស្នេហ៍ ដោយបានទទួលព័ត៌មានពីអ្នកពុំនឹងចូលមកស្នើការ បើតាមព័ត៌មានមកពីទិសបស្ចឹម ជាការពិតឥតប្រ កែកបាន ហើយគូនោះមានជីវធមិ ប្រកបទៅដោយគុណសម្បត្តិ បានជាទីសង្ឃឹម រក្សាគ្នាជាសុខដរាបដល់អវសានកាល ។

ចំពោះកិច្ចការ : ការងារជាចាំបាច់សឹងមានគុណប្រយោជន៍បានចំរើនផលប្រយោជន៍បរិបូរណ៍ ត្រូវបានឡើងថ្នាក់តាមលំដាប់ការ បានទទួលផលរង្វាន់លើកទឹកចិត្តអំពីនាយចៅហ្វាយ តែក្នុងរយៈខែនេះ ដោយផ្តើមឡើងនូវបុព្វហេតុ បង្កើនផលគ្រប់ដំណាក់កាល ។

ក្នុងខែមិថុនា និងកក្កដា ២ខែនេះ លោកអ្នកនាងនឹងបានលុះក្នុងគោលការណ៍សម្រេចឥដ្ឋមនុញ្ញផលជាទីគាប់ចិត្ត ប្រកបទៅដោយសេចក្តីសំបូរសប្បាយ ។

ចំពោះសេចក្តីប្រាថ្នា : លោកអ្នកដែលស្ថិតក្នុងវ័យនេះមានចិត្តប្រាថ្នាយ៉ាងណា រមែងបានសម្រេចតាមយថាហេតុ យ៉ាងនោះ សេចក្តីប្រព្រឹត្តរបស់លោកសុទ្ធតែមានប្រសិទ្ធភាពប្រកបដោយឥទ្ធិពល គួរជាទីពេញចិត្ត កិច្ចការឬវត្ថុនៅជុំវិញខ្លួនសុទ្ធតែប្រកបទៅដោយអត្ថប្រយោជន៍ពេញលក្ខណៈ ។

ចំពោះកិត្តិយស អំណាច យសស័ក្តិ ត្រូវបានឡើងឋានន្តរៈតាមរយៈការ នាទីមុខក្រសួង ត្រូវបានផ្លាស់ប្តូរតំណែងការជាលំដាប់លំដោយ បើនៅទីឆ្ងាយដាច់ស្រយាល ឬចុងកាត់មាត់ញក ក្នុងរយៈពេលនេះត្រូវចាំបាច់ ដូច្នេះវិលចូលមកជិតទីដៅដូចក្រុងតូច-ធំ មានទីប្រជុំផ្សារ សំបូរទៅដោយវត្ថុប្រើប្រាស់ផ្សេងៗ ជាទីពេញនិយមនៃពួកទេសចរគ្រប់វណ្ណៈ ។

ចំពោះលាភផល : ក្នុងរយៈនេះត្រូវបានលាភជើង២ ជាលក្ខៈ បើប្រុសត្រូវបានភរិយាយ៉ាងសមសក្តិ បើស្រីត្រូវបានប្តីមានបុណ្យស័ក្តិនៅរួមសុខរួមទុក្ខជាមួយគ្នាបានសុខចំរើន សំបូរទ្រព្យសម្បត្តិគ្រប់ប្រការ ជាគ្រួសារដ៏រុងរឿង ។

នៅរយៈខែសីហា និងកញ្ញា ២ខែនេះ លោកអ្នកនាងដែលមានជន្មាយុប៉ុណ្ណេះ ចូរត្រៀមខ្លួនប្រុងជើងការ ប្រយ័ត្ន ក្រែងបណ្តាលហេតុឱ្យកើតមានវិបត្តិចំពោះខ្លួនក្នុងបន្ទុកគ្រួសារ ឬពីអ្នកដទៃ ពុំនោះសោត បើមិនជាការចាំបាច់ មិនគួរធ្វើដំណើរទៅកាន់ទីឆ្ងាយ នាទិសខាងលិចឡើយ គ្រោះអាក្រក់នឹងមានមកពីទិសនោះ ថាបើស្រីក្រែងមានគេរំលោភ មើលងាយដល់រូបកាយ បើប្រុសមានសត្រូវចោមរោមប្រមាថកាតទានគួរឱ្យអាម៉ាស់ ឬមួយមានគេណែនាំបំភាន់ស្មារតីឱ្យយល់ ខុស ហ៊ានធ្វើអំពើអាក្រក់ផ្សេងៗ ។

ចំពោះផលប្រយោជន៍ : បើមានការទាក់ទងនឹងលាភផលនៅទិសខាងលិច គ្រានេះមិនគួរឱ្យសង្ឃឹមថាបាន សម្រេចផលសមគោលបំណងបាន បើលោកអ្នកតាំងចិត្តសង្ឃឹមហួសហេតុពេកនោះ លោកក៏នឹងមុខតែមានការខកចិត្ត យ៉ាងធ្ងន់ជាមិនខាន ព្រោះកាលៈទេសៈនេះ មិនមែនជាពេលគួរឱ្យសង្ឃឹមកក់ក្តៅទេ ។

ចំពោះហេតុការណ៍ : មានតែផលអាក្រក់កើតមានឡើង បើតាមការជិតស្និទ្ធជាងគេ គឺការក្តៅក្រហាយ ការឃ្នាំង គំនិតខ្វែងយោបល់គ្នា ការចោទប្រកាន់ ចាប់ទោសអួសដំណើរគ្នារវាងមនុស្សផ្ទុយគ្នា ជាពិសេសត្រូវគេរំលោភយ៉ាង កំរោល ។

ចំពោះភោគផល : ត្រូវនិរាសចាកគូគ្រង ឃ្លាតចាកពីស្ថាន ប្រាស់សេចក្តីសប្បាយ ទទួលរងអំពើទារុណ ភពប្រសព្វរបស់គួរឱ្យខ្ពើមស្អប់ មានទឹកភ្នែកហូរសស្រាក់ ។

លុះចរចូលដល់ខែតុលា និង វិច្ឆិកា ក្នុងរវាង២ខែនេះ លោកអ្នកមានអាយុថ្នាក់កម្រិតប៉ុណ្ណេះ សូមជ្រាបចុះថា សតិអារម្មណ៍របស់លោកអ្នកត្រូវទុក្ខសោកមកសង្កត់ជាប់ តែបើកាលពីខែមុនមានខ្លះហើយ ក្នុងរយៈ២ខែនេះ ក៏អាចស្រាលធូរចុះបានដែរ ថាបើមិនមានខ្លះទេកាលពីខែមុននោះ សូមអស់លោកស្រូតប្រញាប់រកពិធីដោះស្រាយឬបង្ការទុកជា មុនទៅ កុំបណ្តោយឱ្យពេលវេលាកន្លងទៅ ដោយនាំយកជោគសិរីរបស់អស់លោកតាមជាប់ទៅផងហើយ បើកឱកាសឱ្យសេចក្តីទុក្ខក្រៀមក្រំឆ្អៀតផ្សំបណ្តុះបានតាមទំនើងវានៅក្នុងរយៈខែ២នេះ ការណ៍ដែលប្រាកដជាងការណ៍ណាទាំងអស់ គឺត្រូវមានទុក្ខដោយមានគេបង្ខំនាំឱ្យព្រាត់វត្ថុជាទីស្នេហា បើភេទស្រីត្រូវធ្លាក់ខ្លួនដោយកាមរោគចោទឡើង បើភេទប្រុសឈ្លក់គំនិតទៅប្រតិព័ទ្ធក្រៅ ភ្លេចទ្រព្យសម្បត្តិ បុត្រ ភរិយា យល់សថាជាខ្មៅ យល់ត្រូវថាជាខុស សឹងតែប្រាសចាកមនុស្សធម៌តែម្តង ។

ចំពោះវិបាក : លោកអ្នកនាងសូមជ្រាបថា ករណីជាចាំបាច់ក្នុងពេលនេះ សុទ្ធតែពេលពោរពេញទៅដោយផល សៅហ្មងតាមសភាពដែលខ្លួនប្រព្រឹត្តនឹងវត្ថុចោមរោមខ្លួន តែគង់មានពេលណាមួយអាចឱ្យមានសតិអារម្មណ៍ភ្លឺថ្លាបាន ម្តងៗដែរជាហេតុឱ្យងាកបែរពីទុក្ខទោមនស្សទាំងនោះឯង ។

ក្នុងខែ ធ្នូ និងមករា ២ខែនេះ លោកអ្នកមានអាយុចរចូលដល់កម្រិតប៉ុណ្ណេះ មុខជាបានរួចចាកសេចក្តីសៅហ្មងពីពេលមុនពិតហើយ ខណៈពេលនេះពេលសុខសួស្តីរបស់យើងដល់ហើយ ផលសំណាងរបស់យើងត្រូវមានជោគជ័យពេញ លក្ខណៈ ។

ចំពោះហេតុផលជាចាំបាច់ : ទុក្ខក្តៅក្រហាយដែលកើតមានទាំងប៉ុន្មាន១ជាអហោសិកម្មទាំងអស់ គូគ្រងដែលត្រូវព្យុះខ្យល់បោកបក់ឱ្យរសាត់ទៅឆ្ងាយក៏ត្រូវបានវិលត្រឡប់មកជួបគ្នាវិញ របរការដែលត្រូវផ្អាក ឬឈប់ ក៏ត្រូវចាប់ផ្តើមដើរវិញដែរ ទ្រព្យរបស់ដែលរបូតចេញផុតពីដៃទៅ ក៏ត្រូវបានមកវិញគ្រប់គ្រាន់ បើមិនបានដោយត្រង់ៗ ក៏គង់បានមកតាមផ្លូវអមដែរ តិច-ច្រើន តូច-ធំ ស្រេចតែគួរដល់កម្លាំងប្រព្រឹត្ត និងប្រមាណនៃវត្ថុចោមរោមខ្លួន ។

ចំពោះកាលៈវេលា : គ្រាដែលបានមកវិញ បើរបស់ដែលគួរដល់កាលអំណនេះមែន គឺមានមកក្នុងខែទាំង២នេះ ខែណាខែនោះជាប្រក្សត្យ ទិសទីដែលសមទំនងផ្តល់ជោគ គឺមានមកពីខាងទិសបស្ចឹមតែម្យ៉ាង ។

ក្នុងខែកុម្ភៈ និង មីនា ២ខែនេះ លោកអ្នកមានអាយុថ្នាក់ប៉ុណ្ណេះ សឹងបានជួបប្រទះសុភមង្គលវិបុលសុខ បានចំរើនកិត្តិយសឡើង នាទីរកផលបានយ៉ាងបរិបូរណ៍ ។

ចំពោះការងារ : បើធ្វើរាជការ មុខតែនាយចៅហ្វាយប្រគល់កិច្ចការឱ្យកាន់កាប់យ៉ាងធួនតម្រិះវិជ្ជា ហើយមានចិត្តភក្តីស្រឡាញ់ជឿទុកចិត្តក្រៃពេក បើប្រកបរបរពាណិជ្ជកម្មត្រូវបានចំណេញយ៉ាងធំ ហើយងាយផង បើធ្វើការទូទៅអាចឱ្យការនោះមានសភាពធូរទូលាយ ហើយប្រាសចាកគេឥច្ឆាច្រណែនរិះគន់ទៀងផង បើស្វែងរកលាភសូមចរសំដៅទៅខាងទិសបស្ចឹមចុះនឹងបានប្រកបសមបំណងមែន ប្រសិនជាចៃសន្យមានឈឺថ្កាត់ មានឈឺក្បាលជាមូលហេតុ បើរៀបចំសែនព្រេនត្រូវរៀបពែ៤ជ្រុង មានរូត៨ កន្ទោង៤ បាយស-ក្រហមញាំភ្លាសារអាំងដាក់ក្នុងកន្ទោងបាន់រូបបិសាច៤នាក់ រូប ស្រី១នាក់ រូបយក្ខលីដំបង១ រូបអ្នកឈឺ១ សែនរួចយកពែទៅទុកទិសបស្ចឹម បើយ៉ាងយូរណាស់៣ថ្ងៃបានជាសះស្បើយ ប្រាកដ ។

...............................................

## រូបភាពទំព័រ (១០៣)

ប្រុសអាយុបាន ១៤,២២,៣០,៣៨,៤៦ និង ៥៤ ឆ្នាំ ។

ស្រីអាយុបាន ១៨,២៦,៣៤,៤២,៥០ និង ៥៨ ឆ្នាំ ។

លោកអ្នកនាងអាយុប៉ុណ្ណេះ មានព្រឹត្តិការណ៍ផ្សេងៗ ដូចតទៅនេះ :

ចំពោះការសិក្សា : ក្នុងខែ មេសា និង ឧសភា ២ខែនេះច្រើនមានការកង្វល់កើតឡើងរឿយៗ ជាហេតុនាំឱ្យសេចក្តីព្យាយាម និងសេចក្តីប្រព្រឹត្តក្នុងពិធីការសិក្សារយាល ឬនឿយណាយ ពុំនោះមានកើតការស្អុះស្អាប់ គំនិតមិនសូវខ្ជាប់ខ្ជួន ទាសអារម្មណ៍ដោយសារខ្វល់ខ្វាយយកអាសារនាយឬអ្នកធំ ជាពិសេសសតិបញ្ញាចុះអន់ថយ ហើយវល់វល់ច្រើន ។

ចំពោះគូមេត្រី : ក្នុង២ខែនេះ បើលោកអ្នកនាងនៅលីវទ សូមកុំចរទៅណាឆ្ងាយ ខាងទិសពាយ័ព្យ ទោះមានគេពឹងពរឱ្យជួយកំដរក្តី គេបបួលទៅកែកំសាន្តមើលរបាំ ស្តាប់តន្ត្រីក្តី បើជាការមិនចាំបាច់គួរតែអាក់ខានជាដាច់ខាត ព្រោះថានឹងមានហេតុបច្ច័យពុំប្រពៃកើតឡើង បើស្រីនឹងមានការជ្រុលមាត់ភ្លាត់សម្តី ជាហេតុនាំឱ្យខូចកេរ្តិ៍ឈ្មោះ អាស្រូវទាម ខាតផលសួនទ្យលាភ បើភេទប្រុសមុខតែមានខកពាក្យ ធ្លោយសម្តី ជាហេតុនាំឱ្យគេថ្កោលទោសចាប់កំហុសប្រកាន់ថ្នាក់ បើហោចណាស់ក៏គង់ឱ្យខាតប្រយោជន៍មិនខាន បើមិនធំក៏តូច ។

ចំពោះកិច្ចការ : ក្នុងរយៈ២ខែនេះ បើលោកអ្នកសញ្ចរទៅកាន់ទិសពាយ័ព្យ ដោយស្វែងរកលាភក្តី ប្រកបការរបរ ក្តីចេញប្រតិបត្តិការរាជការក្តី ពេលនេះមិនបានផលសមប្រាថ្នាឡើយ ជាការផ្ទុយទៅវិញ មានតែសេចក្តីរំខាន និងបង្កវិនាសផ្សេងៗឡើងតែប៉ុណ្ណោះ ។

ចំពោះសេចក្តីសុខសាន្ត : តាមការពិតសេចក្តីសុខក្នុងរយៈ២ខែនេះ ប្រសិនបើកើតមានក៏មានយ៉ាងស្តួចស្តើង ណាស់ បើសេចក្តីទុក្ខវិញពិតជាមានយ៉ាងមធ្យមតាមផ្លូវពាក្យសម្តី តាមវត្ថុដែលចំណាំទុក ឬបំណងស្រេចហើយ ពុំនោះក្រែងមានមនុស្សម្នាក់នៅជាមួយបណ្តាលហេតុឱ្យកើតមានសេចក្តីព្រួយរំខាន ឬក៏នាំឱ្យខ្លួនយើងរងអំពើទារុណជួសគេម្យ៉ាងទៀតមិនគួរចូលព្រៃធំ ដើរផ្លូវឆ្ងាយម្នាក់ឯង ឡើងភ្នំធ្លោយសម្តីអាចិកំបាំងប្រាប់គេ កិរិយាទាំងអស់នេះសុទ្ធតែប្រកបដោយទុក្ខទោសធ្លាក់ត្រូវអាត្មា ។

ក្នុងខែមិថុនា និង កក្កដា ២ខែនេះ បើលោកអ្នកនាងបានធ្វើអ្វីជាការមិនសមគួរ ឬមានទំនងអាក្រក់ នោះមុខតែបានទទួលផលយ៉ាងជាក់ស្តែងតាមសមគួរតាមកម្លាំងដែលបានធ្វើ បើហោចណាស់ក៏គង់ខូចផលប្រយោជន៍ដែលបម្រុងកើតមានដោយសារសេចក្តីព្យាយាមសាងសន្សំមកពីពេលមុនៗដែរ ហេតុការណ៍ចូរចាំឱ្យជាក់ចុះ ប្រាកដក្នុងគំនិតយ៉ាងមុត មាំ ។

ក្នុងខែសីហា និង កញ្ញា ទាំង២ខែនេះ លោកអ្នកនាងបើនៅលីវ ស្ថិតនៅក្នុងវ័យកម្លោះក្រមុំ មុខតែមានលាភត្រូវបានវត្ថុរបស់ជើង២ ឬជើង៤ មានជីវិត ឬឥតជីវិត ។

ចំពោះរូបមន្តរបស់លាភផល : តាមពិតត្រូវមានលាភជើង២ ហើយមានជីវិត ជាផលប្រសើរលើសលាភទាំងពួងដូចជាមានភពប្រសព្វចិត្តប្រតិព័ទ្ធ រួមស្និទ្ធស្នេហ៍ជាមួយគូមេត្រី គូនោះមានលក្ខណៈសំខាន់ទៅដោយរូបសម្បត្តិ ឬភោគ ស សម្បត្តិ ពុំនោះគូនោះមានគុណសម្បត្តិគ្រប់គ្រាន់ ។

ចំពោះកិច្ចការទូទៅ : បើធ្វើការរាជការក្រោមបញ្ជានាយចៅហ្វាយ ត្រូវបានលាភជាធំជាប្រធាន មេត្តាអាណិត ស្រឡាញ់ កោតសរសើរឬប្រគល់នាទីតំណែងឱ្យយ៉ាងធូនចិត្ត បើជារាស្ត្រសាមញ្ញប្រកបការងារផ្សេងៗ សឹងបានផលគួរ ដល់សេចក្តីប្រាថ្នា និងសមគួរដល់ទំហំការនោះ ។

ចំពោះចិត្តគំនិតនិងអធ្យាស្រ័យ : ក្នុងរយៈ២ខែនេះ មានឱហាតស្រវាំស្រទេញចាប់ប្រកបការងារសឹងតែមិនឈប់ ឈរ ការងារដែលចាប់ផ្តើមឡើងសុទ្ធតែការជឿនលឿន និងសម្រេចបានយ៉ាងចំណាប់ មានគោចោមរោមជួយខ្វាយខ្វល់ គ្រប់ទិសទី ក្នុងអធ្យាស្រ័យវិញមានការចេះពូតផ្គុំត្រសោះអន្ទង ដឹកនាំគេដោយមធ្យោបាយគតិបណ្ឌិតសុទ្ធៗ ។

សភាពដូចពោលនេះសឹងផុសឡើងតាមលំអានសតិបញ្ញាថ្លាផូរផង់ អាស្រ័យហេតុជោគរាសីដួងផ្កាយចូលដល់នាទី ល្អរបស់លោកអ្នកនាងហើយ ។

ក្នុងខែតុលា និងវិច្ឆិកា ខែទាំង២នេះ លោកអ្នកនាងចូលដល់ថ្នាក់"អតិរេកជោគ" គឺត្រូវបានសម្រេចផលយ៉ាង ប្រក្សត្រ តាមភាពពិតនៃសេចក្តីប្រព្រឹត្ត និងវត្ថុនៅក្បែរកិតជុំវិញខ្លួន ។

ចំពោះសេចក្តីប៉ុនប៉ង : បើលោកអ្នកនាងមិនមានគូគ្រងទេ ហើយមានសំណៅដៅទុកពីពេលមុន ឬពេលមិនទាន់ បានសម្រេច ក្នុងពេលនេះត្រូវបានសម្រេចនូវគោលដៅនោះដោយបានស្រួល គឺថាមានហេតុផលទាក់ទាញឱ្យសច្រេមត្រា តែបាន សមដូចបំណងមែនពិត ។

ចំពោះលាភផល : ផលដែលមានប្រសិទ្ធភាពជាងគេក្នុងពេលនេះ គឺសេចក្តីគោរព ស្រឡាញ់ និងសេចក្តីរីករាយ ទោះទៅកាន់ទិសទីនានា សឹងមានគេចូលចិត្តចង់ស្គាល់ ចង់ចងមេត្រីមិត្តជាមួយ ភេទផ្ទុយគ្នាចង់ចងសម្ព័ន្ធភាពស្នេហ៍ស្ទើរ តែទប់មិនបាន ។

ចំពោះនាទីការងារ : កិច្ចការសឹងតែទាំងអស់ដែលលោកអ្នកនាងកាន់កាប់ ឬប្រកបធ្វើត្រូវបានឡើងមួយកម្រិត ទៀត បើយ៉ាងហោចណាស់ក៏គង់មានមិត្តចាស់ណាមួយបបួល ឬចង្អុលទិសដៅឱ្យដំណើរទៅកាន់សេចក្តីរុងរឿង ចំរើន បើ មិនច្រើនក៏តិច តាមពិតរឿងប្រសិនបើឬក្សលក្ខណៈ កំណើតរបស់លោកអ្នកនាងប្រពៃផង នោះគ្មានអ្វីមកជំទាស់បាន ឬ ធ្វើឱ្យអាក់ដំណើររវាតចេញពីសេចក្តីរុងរឿងដ៏ពិសាលភាពយ៉ាងខ្ពស់ និងធំទូលាយនោះឡើយ ។

សេចក្តីសម្រេច : ក្នុងពេល២ខែនេះ លោកអ្នកនាងដែលមានអាយុថ្នាក់នេះ សូមសន្និដ្ឋានក្នុងចិត្តចុះថា ភាពជន ដែលត្រូវសម្រេចឬឡើងនោះ លុះត្រាតែចេញផុតពីទីកន្លែងដើម ហើយឆ្ងាយទៀតផង ពុំនោះត្រូវមានការអន្ទាក់អន្ទាំ បន្តិចក្នុងរវាងការសម្រេច ឬឡើងនោះឯង ដូច្នេះមិនត្រូវបង្អន់កម្លាំងសន្ទុះមានៈឱ្យរួញថយ ឬយោលពីរឿងលំបាកនោះទេ បើធ្វើយ៉ាងនេះបានឈ្មោះថាជាជោគជ័យសម្រាប់លោកអ្នកនាងជាប្រាកដ តាមទិសដែលជាសេចក្តីរុងរឿងចំរើនសម្រាប់ ជោគនេះ គឺកើតមាននៅខាងទិសភាគខាងអាគ្នេយ៍ ។

ខែធ្នូ និងមករា ២ខែនេះ អស់លោកអ្នកមានជន្មាយុចរចូលក្នុងវ័យប៉ុណ្ណេះ សូមជ្រាបថា មុខតែមានហេតុផល ប្លែកបណ្តាលឡើងបន្តិចម្តងៗហើយ ដូចជាសេចក្តីមួងហ្មងចិត្ត គំនិតទីសទាស់ខុសធម្មតា ព្រមទាំងអាការៈទូទៅសឹងមាន សភាពច្រើនទៅដោយការអាប់អួរ និងរចុករចាចិត្តពេក ថាបើភាពយ៉ាងនេះមានឡើងអមជាមួយផ្លូវចិត្ត ហើយមិនយូរ ឡើយ គង់ឃើញហេតុផលមកជន្លិបជន្លូរមិនខាន ។

ចំពោះភាពផ្សេងៗ : សូមប្រយ័ត្នបុត្រធីតាដែលពេញវ័យ មិនគួរបណ្តែតបណ្តោយឱ្យធ្វើដំណើរតាមទំនើងចិត្តទេ ពុំនោះគួរប្រយ័ត្នក្នុងទីប្រជុំ ប្រសិនបើជាចៃដន្យមានអាសន្នឡើង ច្រើនកើតសេចក្តីក្តៅក្រហាយ ឈឺចាប់យ៉ាងខ្លោចផ្សា ព្រោះសត្រូវមាននៅជិតបង្កើយ ឬមួយអ្នកមានអំណាចប្រុងរំលោភដោយប្រការផ្សេងៗ ដោយផ្លូវពាក្យសម្តី បើពុំនោះដោយប្រការប្រយោលក៏មានដែរ ។

ចំពោះហេតុការណ៍ : នៅក្នុងនាទីការងារត្រូវមានសេចក្តីរង្គាលយ៉ាងអមនុស្សធម៌មកលើខ្លួន ជាពិសេសហេតុដែលបណ្តាលឡើងអំពីអ្នកផ្ទុយភេទ ឬអ្នកស្នាក់អាស្រ័យជាមួយ តាមពិតការចាក់រុក បៀតបៀន តែបន្លំ មើលងាយ រិះ គន់ទាំងនេះត្រូវធ្លាក់មកលើអស់លោកអ្នកនាងដែលមានអាយុរវាងប៉ុណ្ណេះ ហើយមានលើខែទាំង២នេះឯង ។

ខែកុម្ភៈ និងមីនា ក្នុងរយៈ២ខែនេះ លោកអ្នកនាងគប្បីប្រយ័ត្នខ្លួនឱ្យបានជិតដល់បន្តិច ក្រែងហេតុការណ៍ជាផ្លូវគ្រោះត្រូវកើតមានដោយចំពោះ ឬតាមផ្លូវអមបណ្តាលឱ្យរង្គោះរង្គើ មានសេចក្តីសៅហ្មង ទុក្ខព្រួយ ឈឺចាប់រំខានផ្សេងៗ

ចំពោះរូបមន្តវត្ថុ : ឬសគល់របស់រឿងរ៉ាវ គឺមនុស្សភេទផ្ទុយជាអ្នកបង្កការចលាចល ពុំនោះរឿងនោះសម្រាប់ធ្វើឱ្យមានមន្ទិលដល់កិត្តិយសខូចសិទ្ធិអំណាច បង់អសារនៅអានុភាព ខ្វះឥទ្ធិពលសាបសូន្យផលប្រយោជន៍ ។

សភាពការណ៍ដូចថានេះ ប្រសិនបើលោកអ្នកនាងជៀសវាងបាន ក៏នៅមានគ្រោះចៃដន្យម្យ៉ាងទៀត គឺកាយមាន រោគកាយប៉ះទង្គិចគ្រាំគ្រា បែកបាក់ មុខដាច់ ជាហេតុឱ្យមានវេទនាឈឺចុកចាប់ ឬមានជំងឺតម្កាត់ពុំសុខកាយសប្បាយចិត្ត ថាបើមានហេតុការណ៍មួយកើតមានឡើង គប្បីរៀបចំពិធីសែនរំដោះគ្រោះចៃដន្យចូរធ្វើពែវរួត កន្ទោង៥ បាយសក្រហមញាំភ្លាដាក់កន្ទោសប៉ុន រូបយក្ខកាន់ដំបង១ រូបស្តេចគ្រុឌ១ រូបស្រី១ បិសាច៨នាក់ សែនរួចយកពែទៅទុកដាក់ខាងទិសពាយ័ព្យ កន្លងទៅ៣ថ្ងៃបានជាសះស្បើយសមបំណង ។

....................................

## រូបភាពទំព័រ (១១០)

ប្រុសអាយុបាន ១៥,២៣,៣១,៣៩,៤៧ និង ៥៥ឆ្នាំ ។

ស្រីអាយុបាន ១៨,២៦,៣៤,៤២,៥0 និង ៥៨ ឆ្នាំ ។

លោកអ្នកនាងក្នុងកាលជន្មាយុប៉ុណ្ណេះ សឹងមានព្រឹត្តិការណ៍កើតមានតាមរយៈខែដូចតទៅនេះ :

ក្នុងខែមេសា និង ឧសភា ២ខែនេះ បើគួរដល់កាលៈទេសៈប្រឡងប្រជែងដើម្បីឡើងថ្នាក់នោះ មុខជាមានសង្ឃឹម ច្រើនដែរ ក្នុង១០ភាគ សង្ឃឹមបាន៨ភាគថាបានឡើងថ្នាក់ ប្រសិនបើប្រឡងយកសញ្ញាបត្រមធ្យម ឬ ជាន់ខ្ពស់ មាន សង្ឃឹមក្នុងភាគ១0 បានភាគ៧ ថាជាប់ជាស្ថាពរ បើប្រឡងចូលធ្វើការ ឬប្រជែងដើម្បីឡើងកាន់មុខតំណែង ក្នុង១០ភាគ មានសង្ឃឹម ៦ ភាគ ថាបានជាប់ពិន្ទុលេខចូលធ្វើការ ។

ចំពោះគូរួមរស់ : បើលោកអ្នកនាងនៅលីវសុទ្ធសាធទេ ក្នុងរយៈនេះមុខជាបានជួបប្រទះគូស្នេហ៍ ហើយគូនោះស្ថិតនៅភូមិតំបន់ឆ្ងាយអាត្មា ឃើញគ្នាកាលណាក៏កើតសេចក្តីប្រតិព័ទ្ធគួចចិត្តចង់ចងសម្ព័ន្ធកាលទំនងត្រឹមត្រូវល្អ ។

ចំពោះកិច្ចការ : បើធ្វើកិច្ចការ ត្រូវបាននាយចៅហ្វាយយល់ឃើញនូវសេចក្តីស្មោះត្រង់របស់អាត្មា ចំពោះនាយ និង កិច្ចការ បើប្រកបអាជីវកម្មផ្សេងៗ ត្រូវបានកម្រៃផលជាបង្គួរ តាមហេតុផលដែលអាត្មាប្រព្រឹត្ត និងព្យាយាម ។

ចំពោះលទ្ធផល : ផលដែលសក្តិសិទ្ធិជាងគេ គឺរង្វាន់លើកទឹកចិត្ត គុណបំណាច់ សេចក្តីស្រឡាញ់រាប់មុខ ទឹកចិត្ត ស្មោះស ការទទួលស្គាល់អំពីលោកជាធំប្រធានកិច្ចការ សភាពយ៉ាងហ្នឹងកើតមានដល់លោកអ្នកនាង ស្ថិតនៅក្នុងលក្ខណៈ ខែខែនេះ ។

ក្នុងរយៈខែមិថុនា និងកក្កដា ២ខែនេះ លោកអ្នកនាងមុខតែមានជោគជ័យធំក្នុងសង្គមការ ឬក្នុងវង់កិច្ចការ ការដែលលោកអ្នកនាងបំណងដៅទុកយ៉ាងណាៗ នោះត្រូវឈានសំដៅទៅកាន់សេចក្តីសម្រេចនៅក្នុងរយៈពេលនេះឯង តែការដែលសម្រេចទៅបានក៏មិនហួសពីនិស្ស័យនៃវត្ថុធាតុដែលចោមរោមជុំវិញខ្លួននោះដែរ តាមធាតុពិត ការផ្លាស់ប្តូរទី ស្ថានដូរមុខការងារនាទីមុខរបរ សភាពយ៉ាងនេះត្រូវបានលោកអ្នកនាងជួបប្រទះយ៉ាងជាក់ស្តែង ហើយថ្លៃថ្នូរទៀតផង ។

ក្នុងខែសីហា និង កញ្ញា ទាំង២ខែនេះ លោកអ្នកនាងដែលមានអាយុប៉ុណ្ណេះ សូមចាំទុកក្នុងចិត្តឱ្យបានជានិច្ចថា គ្រោះកាចមុខតែកើតមានចំពោះអាត្មាមិនខាន បើមិនធំក៏តូច ។

ចំពោះហេតុការណ៍ : មិនគួរយាត្រាចេញទៅកាន់ទីឆ្ងាយនាទិសខាងជើងឡើយ សត្រូវប៉ងយាយី ការវង្វេងភាន់ច្រឡំមានការថ្នាំងថ្នាក់រវាងអ្នកដំណើររួម មានប៉ះពាល់នាំឱ្យសៅហ្មងដល់អវៈយវៈ សភាពទាំងនេះសឹងមានកើតដល លោកអ្នកនាង បើមិនធំក៏ស្រាល ហេតុនេះសូមប្រុងសតិបញ្ញាប្រយ័ត្នសព្វកិច្ចការទូទៅទាំងជិតឆ្ងាយ ។

ក្នុងខែតុលា និង វិច្ឆិកា ក្នុងរយៈ២ខែនេះ សេចក្តីរាប់កិត្តិយស បច្ចាមិត្តបុករុក សត្វកំណាច ឬមានពិស សត្រូវ ចោមរោម សភាពយ៉ាងនេះកើតមានឡើងមកពីខាងទិសឧត្តរ លោកអ្នកគប្បីវៀរចាកអំពើចចេសរឹងរូសទើបជៀសផុតពី ចៃដន្យទាំងនេះផុត ប្រសិនបើជាមានក៏មានដោយដឹងខ្លួនជាមុន ដូចអ្នកដើរជាន់បន្លាដោយឃើញ ឬដឹងថាមានបន្លា ថាបើ មុតក៏រាក់ដែរ ។

ចំពោះកិច្ចការ : លទ្ធផលជាចាំបាច់ គឺគំនិតកាន់ច្រឡំព្រោះចិត្តប្រមាថ សភាពការណ៍ជាក់ស្តែងជាងលទ្ធផល ដទៃៗទៀត មិនតែប៉ុណ្ណោះសឹងតែបណ្តាលឱ្យមានភ័យយ៉ាងធំកើតឡើង ព្រមទាំងសេចក្តីក្តៅក្រហាយរកទីបំផុតគ្មាន ។

ក្នុងខែធ្នូ និង មករា ក្នុងរយៈ២ខែនេះ លោកអ្នកនាងតែងមានអាយុដល់ក៏រិតនេះ មុខតែមានសង្ឃឹមច្រើន គឺថានឹងមានផលប្រយោជន៍យ៉ាងធូនចិត្ត ផលប្រយោជន៍ដែលធ្លាក់ចុះ ឬបង់ខាតពីពេលមុន ពុំនោះខ្លួនលោកអ្នកនាងកាលពីពេលមុនឃ្លាតចាកកន្លែង ភូមិឋាន ឬឃ្លាតចាកនាទីមុខការ និងមុខរបរការក្នុងពេលនេះ ត្រូវបានវិលត្រឡប់មកកាន់ទី ឋាន មុខតំណែងដើម ឬក៏មុខតំណែងដទៃ តែមានសភាពប្រដិប្រសងនឹងនាទីមុខតំណែងជាន់មុខដែរ ម្យ៉ាងទៀតលាភ ផល សេចក្តីសុខចំរើន យសសក្តិ សេចក្តីរុងរឿង មុខតែបានឱកាសកើតមានដល់លោកអ្នកនាងជាប្រក្យត្យ ។

ក្នុងខែកុម្ភៈ និង មីនា ២ខែនេះ ជាជោគជ័យធំរបស់លោកអ្នកនាងមែនពិត គ្រួសារក្តី ទ្រព្យមានជីវិតក្តី កិត្តិយស និងសេរិភាពក្តី សភាពការណ៍ទាំងនេះ លោកអ្នកនាងមុខជាបានភពប្រសប់យ៉ាងពេញលក្ខណៈ ហើយជាស្ថាពរផង ។

ចំពោះគូវាសនា : លោកអ្នកនាងមានអាយុប៉ុណ្ណេះ ក្នុងរយៈនេះ បើស្ថិតនៅក្នុងវ័យកម្លោះក្រមុំ មុខជាបានគូគ្រង យ៉ាងពេញចិត្ត បើមានការនិរាសគ្នា ពេលនេះត្រូវបានជួបគ្នា រក្សាគ្នាជាសុខសាន្តដរាបដល់ទីបំផុត បើធ្វើការរាជការត្រូវ បានឡើងយសសក្តិឬទ្ធិអំណាច ជាពិសេសលោកអ្នកធ្វើការខាងទ័ពសឹក ពេលនេះនឹងបានបរិបូរណ៍ទៅដោយថ្វីដៃ ដែល មានជាញជ័យគ្រប់លក្ខណៈការ គឺថាបានដល់នូវភាពជាអ្នកមុខការតាមសមគួរ ដល់សេចក្តីប្រព្រឹត្តិប្រតិព័ទ្ធរបស់អាត្មា ប្រ

សិនបើមានឈឺ ពុំជា សូមធ្វើពែ៥រួត កន្ទោង៤ បាយស ក្រហមញាំភ្លាសារអាំង ចំអាប បង្អែមដាក់កន្ទោង ធូបអុជ សែន រូចនាំយកទៅទុកនាទិសខាងជើង ប៉ានរូបស្វា១ រូបបិសាច៦ រូបស្នងខ្លួន១ ដាក់ក្នុងពៃសែន ៣ថ្ងៃសះស្បើយជាស្រឡះមែន ពិត ។

.........................................

## រូបភាពទំព័រ (១១៥)

ប្រុសអាយុបាន ១៦,២៤,៣២,៤០,៤៨ និង ៥៦ ឆ្នាំ ។

ស្រីអាយុបាន ១២,២០,២៨,៣៦,៤៤,៥២ និង ៦០ ឆ្នាំ ។

លោកអ្នកនាងមានអាយុប៉ុណ្ណេះ មានព្រឹត្តិការណ៍ផ្សេងៗប្រចាំអាយុ ដូចតទៅនេះ គឺ :

ក្នុងខែមេសា និងឧសភា ២ខែនេះ សឹងមានការកង្វល់ចំពោះខ្លួន ឬចំពោះក្រុមគ្រួសារ គណៈញាតិពន្ធមិត្ត រឿងនេះកើតឡើងដោយសារខ្វែងមតិយោបល់គ្នា ជាហេតុឱ្យមានការស្មោកស្មានរង្គាលចិត្តដល់គ្នានិងគ្នា ត្រូវនិរាសចាកវត្ថុទាំងនេះដោយបង្ខំចិត្ត ។

ចំពោះការសិក្សា : ត្រូវមានមិត្តនាំឱ្យទម្លាក់សេចក្តីព្យាយាមចោល ត្រេកត្រអាលភ្លើតភ្លើនទៅក្នុងល្បែងផ្សេងៗ ពុំនោះមានចិត្តនឿយណាយណាស់ ធុញថប់ ស្អប់ខ្ពើមការងារដែលចាំបាច់ បើមិនដូច្នេះទេត្រូវគេស្តីបន្ទោស ដោយហេតុតែខ្លួនមានសេចក្តីប្រហែសធ្វេស ឬភាន់ច្រឡំអ្វីមួយ ហើយមានសេចក្តីអៀនអន់ បោះបង់ការសិក្សា ដើរចេញចោលការ សិក្សា ។

ចំពោះការងារ : ត្រូវនាយ ឬមេការប្រកាន់ថ្នាក់ បន្ទោសស្តីប្រមាថកាតទាន ជាងនេះទៀត គេចោទចាប់ឱ្យសង ថ្លៃផ្សេងៗ ដែលជាហេតុបណ្តាលឱ្យក្តៅចិត្តទប់មិនបានហ៊ានតបតវិញពេញទី ។

ចំពោះសេចក្តីស្មោះត្រង់ : ត្រូវនាយបញ្ហាការក្លែងមួលបង្កាច់ បណ្តេញបំបរដោយអាការបំពារបំពាន ឬមានហេតុទំនាស់យ៉ាងធ្ងន់ធ្ងរដល់បក្ខពួកក្រុមដែលគេធ្លាប់ជឿទុកចិត្ត គេដកសេចក្តីទុកចិត្ត ហើយរំលាយសិទ្ធិអំណាចអាត្មាចោល ។

ក្នុងខែមិថុនា និង កក្កដា ២ខែនេះ លោកអ្នកនាងមានអាយុប៉ុណ្ណេះ មុខជាបានទទួលសេចក្តីក្តៅក្រហាយ ឬទុក្ខ ព្រួយតែម្តង ដូចជាធ្វើដំណើរចេញចាកទីកន្លែង ចេញពីមុខការធម្មតា បង់ខាតទ្រព្យសម្បត្តិ ឃ្លាតចាកមិត្តភក្តិ មានសេចក្តី ពិរោធគ្របសង្កត់ចិត្តចងគំនុំកាន់តែកញ្ច្រោលខ្លាំង អាការទាំងនេះវាដុះជាប់ក្នុងគំនិតអធ្យាស្រ័យនៃលោកអ្នកនាង ជាពិសេសលោកអ្នកនាងនឹងលង់ចិត្តផ្តោយគំនិតថប់ដង្ហើមទៅក្នុងសភាពជាមនុស្សផ្សងព្រេង ។

ហេតុនេះលោកអ្នកនាងចូរប្រយ័ត្នខ្លួនក្នុងដំណាក់កាលនេះឱ្យបានជិតដល់បន្តិច ទើបជៀសផុតពីគ្រោះអាសន្ននៃដន្សដូចពោលនេះបាន ។

ក្នុងខែកញ្ញា និង សីហា ២ខែនេះ លោកអ្នកនាងមានសេចក្តីរីករាយកក់ក្តៅខ្លះ បើមិនច្រើនក៏តិចមិនខានឡើយ តាមពិតលោកអ្នកមុខជាបានទីពឹងពុំនាក់យ៉ាងមាំមួន និងស្ថេរភាព ។

ចំពោះសេចក្តីសុខ : នឹងបានក្រេបជញ្ជក់រសជាតិស្នេហ៍យ៉ាងដំពើប ដោយគូស្នេហ៍ប្រគល់សេចក្តីសប្បុរសអស់អញ្ចិត្តចង់ប្រតិព័ទ្ធយ៉ាងស្មោះចំពោះអាត្មា បានភពប្រសប់មិត្តមានចិត្តភក្តីយ៉ាងក្រៃពេក បានទទួលផលប្រយោជន៍សមនឹងគោលដៅមែនពិត ។

ចំពោះកិច្ចការ : បើជាឱកាសហុចឱ្យប្រឡងចូលធ្វើការ ឬរកការធ្វើមុខតែបានជាប់ ឬបានការធ្វើ តែកិច្ចការដែលត្រូវសម្រេចនោះសឹងស្ថិតនៅក្នុងសភាពបម្រុង ឬពិសោធន៍នៅឡើយ ថាបើការនោះមានលក្ខណៈធ្ងន់ ឬធំហួសសមត្ថភាព អាត្មាត្រូវលោកជាធំប្រធានកំពុងលៃលកធ្លាក់ឆ្នៀតស្ទាបស្ទង់ប្រគល់ឱ្យដោយសេចក្ដីអនុគ្រោះ (ពេលនេះបើឫក្សកំណើតចង្អុលនាទីផ្សំផងនោះ ជាការប្រសើរឥតប្រែក្លាយកើត) ។

ក្នុងខែតុលា និង វិច្ឆិកា ២ខែនេះ លោកអ្នកមានអាយុប៉ុណ្ណេះចូលដល់ជោគល្អហើយ គោលដៅរបស់លោកអ្នកបានប្រព្រឹត្តយ៉ាងសមសួននិងកិរិយាអប់រំមែនពិត ដូចជាកិច្ចការបម្រើរដ្ឋ ចូលកាន់ការរដ្ឋ ធ្វើការផ្ទាល់នាយចៅហ្វាយ ទទួលបន្ទុកកិច្ចការព្យាបាលបរិស័ទ ទទួលបញ្ជាពីអ្នកធំ និងចេញប្រតិបត្តិការទូទៅ តាមពិតសភាពការណ៍មានលក្ខណៈដូច ពេលនេះសឹងមានលទ្ធភាពប្រសើរបំផុត គឺថានឹងបានសម្រេចគ្រប់ប្រការ ។

ចំពោះលាភផល : ផលដែលត្រូវទេសៈកាលៈត្រូវកើតមានក្នុងរយៈពេលនេះ ជាលាភហៅថា "សុខលាភ" មានលាភបានដោយងាយស្រួល បានដោយត្រជាក់ចិត្ត បានដោយមិនបាច់បញ្ចេញថ្នូរ បានដោយលើសលប់ ដូចជាបានដោយត្រូវលេខឆ្នោត បានដោយរើសបានជាដើម ។

ចំពោះសេចក្ដីសុខសាន្ត : បច្ចាមិត្តក្នុងរឿងនេះមិនមានជាដាច់ខាត សុខក្នុងឋានៈនៃការងារ ដូចជាទីលំនៅ មុខ របរការ គ្រឿងឧបភោគ-បរិភោគ គ្រឿងសម្រាប់សព្វរជាចាំបាច់ បរិពារចោមរោម សភាពដូចពេលនេះបានសម្រេចដ៏ វិបុល ប្រកបទៅដោយសេចក្ដីរៀបរយ និងរុងរោចន៍ តាមសមគួរដល់កម្លាំងប្រព្រឹត្ត និងប្រតិបត្តិប្រក្រតីរបស់អាត្មា ។

ក្នុងខែធ្នូ និង មករា ២ខែនេះ លោកអ្នកនាងដែលស្ថិតនៅក្នុងដំណាក់កាលអាយុប៉ុណ្ណេះ មុខតែបានផលប្រយោជន៍យ៉ាងសុទ្ធតែថ្មីៗ ដូចជាកិច្ចការប្រឡងឡើងថ្មី គំនិតកិតឡើងក៏ថ្មី សេចក្ដីប្រព្រឹត្តប្រកាន់ខ្ជាប់ក៏ថ្មី លទ្ធផលក៏បានយ៉ាងប្លែកៗពីធម្មតា តិចឬច្រើន តូចឬធំអាស្រ័យលើការព្យាយាម និងវត្ថុដែលនៅក្បែកកិតជិតជុំវិញខ្លួនលោកអ្នកនាង នោះឯងតែគួរឱ្យសង្ឃឹមមាំទៅលើលាភផលខាងអចលនវត្ថុច្រើនជាងលាភផលជាអចលនវត្ថុ ។

ចំពោះការងារ : ប្រកបកិច្ចការដែលបានសម្រេចក្នុងរយៈពេលនេះមានប្រសិទ្ធភាពលែងរញ្ជួយបានហើយ ដោយ នាយធំ ឬនាយក ការជឿស្ដាប់ទុកចិត្ត យល់ស្របឥតរឹងទទឹងប្រកែក ឬរង្គាសសោះឡើយ មានសិទ្ធិជោគក្នុងកិច្ចការគ្រប់ គ្រាន់ ។

ចំពោះឥទ្ធិពល : មានថ្វីមាត់យ៉ាងសំខាន់ បញ្ញាភ្លឺស្វាងអាចយល់សព្វច្រក ពោលគឺការអ្វីសឹងប្រកបតាមសម្ដីដូច ដៅទុក ការក្រ ការងារ ឬរាក់ជ្រៅយ៉ាងណាក៏ដោយ បញ្ញាប្រើការពិចារណា ស្ទាបស្ទង់ប្រមើលតាមដានឃើញ បានឥតកំ បាំងសោះ ពេលនេះជាការល្អសំខាន់បំផុតសម្រាប់ជីវិតប្រព្រឹត្តទៅ១ខណៈ ។

ក្នុងខែកុម្ភៈ និង មីនា ទាំង២ខែនេះ លោកអ្នកនាងមុខជាបានដល់នូវជោគជ័យយ៉ាងធំ គឺថាធ្វើការរាជការនិងបានឡើងបុណ្យបានស័ក្តិយសជាន់ខ្ពស់ បានជាមេបញ្ជាគេទាំងពួង មានឥស្សរភាពច្រើន ទទួលការខុសត្រូវផ្ទាល់ខ្លួន បានសំបូរសប្បាយយ៉ាងធូរទូលាយ តាមពិតរឿងដែលបានជាប្រក្សត្យ ក្នុងរយៈពេលនេះមិនមានព្រំដែនឡើយ តែដែលសំខាន់គឺហួសពីគោលដៅ ប្រសិនបើឫក្សជតាល្អផ្សំផង ។

ក្នុងរយៈ១២ខែនេះ បើមានឈើថ្កាត់ពុំជា ចូរធ្វើពែ៤ជ្រុង មានរូត៨ កន្ទោង៦ ប៉ុនរូបយក្ខកាន់ដំបង១ រូបបិសាច៨ នាក់ រូបស្នងអ្នកជំងឺ១ ប្រដាប់បាយស ក្របាមញាំភ្លាសារអាំង ដាក់ក្នុងកន្ទោងសែន រួចយកទៅទុកដាក់នាទិសព្វាសាន ។

អាការដែលឈឺ ច្រើនឈឺក្បាល វិលមុខ ទឹកចិត្តមួរម៉ៅ ញ័រទ្រូង ញ័រប្រាណ ឬ ភ័យច្រើន ពុំនោះទល់លាមកផង ។

.........................................................

**រូបភាពទំព័រ (១២១)**

ប្រុសអាយុបាន ១៧,២៥,៣៣,៤១,៤៩ និង ៥៧ ឆ្នាំ ។

ស្រីអាយុបាន ១៣,២១,២៩,៣៧,៤៥,៥៣ និង ៦១ ឆ្នាំ ។

លោកអ្នកនាងក្នុងរយៈកាលនេះ ជាកាលដ៏សមគួររបស់ខ្លួនហើយ នៅក្នុងដំណាក់កាលអាយុប៉ុណ្ណោះ សឹងមានព្រឹត្តិការណ៍ដូចតទៅ :

ក្នុងខែមេសា និង ឧសភា ខែទាំង២នេះ ជាខែប្រកបទៅដោយសុវត្ថិភាពសព្វបែបយ៉ាង ចំពោះអ្នកនៅវ័យលីវត្រូវបានលាភមិត្តមកពីខាងទិសបូព៌ា ពុំនោះត្រូវបានជួបគូគ្រង ឬសង្សារយ៉ាងគាប់ចិត្តពេញចំណុចអធ្យាស្រ័យ មានសោភ័ណភាពសក្តិសម ប្រកបទៅដោយចរិយាសម្បត្តិថ្លៃថ្នូរ មានអំបូរប្រហែលអាត្មាខ្លួន ល្មមឱ្យចងសម្ព័ន្ធមេត្រីយកធ្វើជាមេគ្រួសារសម្រាប់អនាគតបាន មានសាមគ្គីរសមិនប្រែក្លាយទៅតាមសាហាវផ្សេងៗឡើយ គូដែលបានចងមេត្រីចិត្តក្នុងរយៈពេលនេះពិតជាគូប្រចាំជីវិត ។

ពុំនោះសោត បើជាអ្នកមានគូគ្រងហើយ ត្រូវបានជួបមិត្តមានភក្តីដល់គ្នានិងគ្នា ល្មមឱ្យទីពឹងបានគ្រប់កាលៈទេសៈ ប្រសិនបើជាករណីសិក្សា គឺសិស្សានុសិស្សត្រូវបានជួបជួនមិត្តជាមួយមនុស្សភេទផ្ទុយគ្នា យកគ្នាធ្វើជាមិត្តយ៉ាងសមភាព និងជាភាតរភាពផង ។

ចំពោះលាភផល : របស់ដែលត្រូវបានយ៉ាងសមគួរទីបំផុត គឺវត្ថុមានជីវិត ប្រសិនបើបានវត្ថុដូចបានពោលនោះ មែនវត្ថុនោះមានលក្ខណៈជើង២ ប្រាកដជាលក្ខណៈដទៃៗ មិនតែប៉ុណ្ណោះ សេចក្តីសុខមនោរម្យក៏សឹងកើតមានបន្ថែមជាកម្លាំងលើភ័សផលដែលបានមកនោះរឿយៗ ។

ក្នុងខែមិថុនា និង កក្កដា ២ខែនេះ លោកអ្នកនាងដែលមានជន្មាយុប៉ុណ្ណោះ មុខជាបានផលសេចក្តីសម្រេចគោលការណ៍ជាស្ថាពរ បើក្នុងរបៀបប្រមូលផ្តុំថាត្រូវកើតបានសង្គមគ្រួសារ ដូចជារៀបអាពាហ៍ពិពាហ៍ជាមួយគូសង្សារ ត្រូវបានគេជួយអបសាទរ ជួយលើកតំកើង និងបានទទួលកិត្តិយស ជាពិសេសត្រូវរួមរស់ជាមួយនិងគូស្នេហ៍ ប្រកបទៅដោយសេច ក្តីរីករាយសំបូរសប្បាយយ៉ាងភិយ្យោភាពរ ។

ចំពោះជោគជ័យ : ក្នុងរយៈនេះបានសុវត្ថិជោគ គឺជាជោគមានលក្ខណៈ ជាពិសេសនៅត្រង់រួមសុខជាមួយគូជីវិតដែលខ្លួនមិនទាន់បាន ធ្លាប់ភពប្រសព្វមកនោះឯង ហើយជាគូដែលនាំមកនូវសេចក្តីរុងរឿង សុខសន្តិភាពដរាបអវសាន ។

ក្នុងខែសីហា និង កញ្ញា ទាំង២ខែនេះ លោកអ្នកនាងដែលមានអាយុក្នុងដំណាក់កាលនេះ សូមតាំងចិត្តអត់ធ្មត់ និងប្រុងប្រយ័ត្នខ្លួនឱ្យបានគ្រប់អំពើ ទោះក្នុងសភាពណាក៏ដោយ ជាពិសេសគួរប្រយ័ត្នក្នុងបន្ទុកក្រុមគ្រួសារ ដូចជាការ ចាក់រុកបៀតបៀនស្វែងរកកំហុសរវាងផ្ទៃក្នុងជាការចាំបាច់ គូស្វាមីភរិយាមានការកន្ទែកចិត្តគំនិតគ្នា រហូតដល់ការបែកឃ្លាតចាកគ្នារវាងគ្រានេះ ។

AZCambodia.com  ABCCambodia.com  AngkorDaily.com  AngkorPost.com  AngkorLink.com

បើពុំបុត្រធីតា ឬបាវព្រាវមានការលលាក់ពុតប្រព្រឹត្តអនាចារផ្សេងៗ បើហោចណាស់ក៏ទ្រព្យមានជីវិតត្រូវខ្ចាត់ ភ្លាត់វង្វេងសាន់តាមហ្វូងដទៃ ជាហេតុនាំឱ្យមានទើ្បយព្រួយ រងសេចក្តីចង្អៀតចង្អល់ចិត្ត ប្រសិនបើអ្នកម្ចាស់ជតាដឹងខ្លួនហើយប្រុងប្រៀបប្រណិបតន៏អប់រំខ្លួនឱ្យជិតដល់ទើបជៀសចាកអន្តរាយនេះបាន ព្រោះរឿងនេះជាគ្រោចរះមែនពិត ។

ក្នុងខែតុលា និង វិច្ឆិកា ខែទាំង២នេះ មានព្រិត្តិការណ៏តឹងតែងបន្តិច លោកអ្នកនាងមានអាយុល្បាក់នេះ មុខជាត្រូវជួបនឹងសេចក្តីខ្លោចផ្សាចិត្ត សេចក្តីធុញថប់ គំនិតអណ្តែតអណ្តូង ការសោកសៅ និងអំពើរំលោភបំពានប្រមាថមើលងាយដោយចំពោះ ការនេះរកអត់ឱនមិនកើត តាមពិតជាវិបត្តិផ្ទៃក្នុងតែម្តង សូមលោកអ្នកនាងចាត់ជាបន្ទាន់ដើម្បីបង្កាកុំឱ្យវិបត្តិរាលដាលរីកសាយ ឆ្លងដល់អនាគតវាសនា ។

ក្នុងខែធ្នូ និង មករា ២ខែនេះ លោកអ្នកនាងត្រូវមានភ័ព្វសំណាងបានវិលមកជួបនឹងលាភផល យសសក្តិអំណាច និងសេចក្តីរីករាយ ព្រមជាមួយសេចក្តីសប្បូរសប្បាយ ។

ចំពោះទិសដៅ : បើលោកអ្នកនាងបានជួបនឹងសុភមង្គលពីទិសបូព៌ា នោះជាការប្រសើរសម្រាប់លោកអ្នកនាង មែនហើយការឃ្លាតចាកពីវត្ថុជាទីស្នេហាពីពេលមុន ក្នុងពេលនេះត្រូវបានជួបដល់វិញ បើមិនចំពោះក៏គង់តាមសភាពអម ដែរ វត្ថុដែលបានភពប្រសប់ក្នុងពេលនេះចាត់ទុកថាជាវត្ថុប្រណីត មានលក្ខណៈប្រកបទៅដោយស្នេរភាព ឬថាមានចំណុចសំខាន់គួរឱ្យពឹងអាងបានសព្វយ៉ាង ។

ក្នុងខែកុម្ភៈ និងមីនា ខែនេះមុខជាបានឡើងឋានៈ គួរដល់កម្លាំងការងារ សេចក្តីប្រព្រឹត្ត និងវត្ថុចោមរោមជុំវិញខ្លួនយើងត្រូវបានបរិបូរណ៏ទៅដោយសេរី បើឈប់ធ្វើការនឹងបានធ្វើការវិញ បើប្រកបរបរការមានខាតបង់ ពេលនេះត្រូវបានចំណេញកំរៃផលធួនល្មមសមប្រាថ្នា បើសមាគមផ្តើមកិច្ចការរួមនឹងបានលទ្ធផលល្អគួរជាទីរីករាយ វត្ថុប្រាថ្នាត្រូវ សម្រេចសេចក្តីសង្ឃឹមទុកត្រូវបានគេជួយជ្រោមជ្រែងឧបត្ថម្ភពិសេសបំផុត គឺសម្បត្តិយ៉ាងត្រកាលដែលខ្លួនមិនធ្លាប់បាន ពេញកម្មសិទ្ធិពេលនេះត្រូវបានជា"ឯកលាភ" ។

បើមានឈឺថ្កាត់ក្នុងរយៈ១២ខែនេះ ខែណាមួយ គប្បីធ្វើពៃ៦រួត កន្ទោង៤ បាយស ក្រហមញាំភ្លាសារអាំងដាក់ កន្ទោងប៉ុនរូបស្តេច១ ទ្រង់កាន់ត្រីសូល៍ រូបយក្ខកាន់ដំបង១ រូបបិសាចពីរនាក់ រូបស្នងខ្លួនអ្នកជំងឺ១នាក់ សែនហើយយកពៃទៅចោលនាទិសបូព៌ា ៣ថ្ងៃជាសះស្បើយហោង ។

.....................................................

## រូបភាពទំព័រ (១២៦)

ប្រុសអាយុបាន ១៨,២៦,៣៤,៤២,៥០ និង ៥៨ ឆ្នាំ ។

ស្រីអាយុបាន  ១៤,២២,៣០,៣៨,៤៦ និង ៥៤ ឆ្នាំ ។

លោកអ្នកនាងដែលមានជន្មាយុគម្រប់ដូចខាងលើនេះ មានព្រឹត្តិការណ៏ប្រចាំអាយុដូចតទៅ :

ភារៈច្រណែន ហិង្សា ការគុំគួន នេះជាភាពអាសន្នសឹងកើតមានដល់លោកអ្នកនាងក្នុងខែមេសា និងឧសភា បើលោកអ្នកប្រុងប្រយ័ត្ន ទើបមានសង្ឃឹមថាជៀសវាងបាន តាមការពិតនៅក្នុងខែទាំង២នេះមុខជាបានទទួលនូវសេចក្តីក្តៅ ក្រហាយការរុកគួន អំពើបៀតបៀនផ្សេងៗអំពីសំណាក់ក្រុមគ្រួសារ ឬក៏ញាតិមិត្តជិតខាង ជាពិសេសការការរំលោភយ៉ាង ទារុណ ។

AZCambodia.com  ABCCambodia.com  AngkorDaily.com  AngkorPost.com  AngkorLink.com

ចំពោះហេតុការណ៍ ៖ បើលោកអ្នកនាងស្ថិតនៅក្នុងវ័យលីវ គួរប្រយ័ត្នអំពីការជ្រែកជ្រៀតមុខគ្នាក្នុងរឿងស្នេហា បើមានគូគ្រងហើយគួរប្រយ័ត្នមានហេតុស្មោកស្មាន រវាងក្រុមឬញាតិមិត្តអំពីសេចក្ដីច្រណែនឫស្យា ។

ចំពោះកិច្ចការងារ ៖ ទ្រព្យមានជីវិត គ្មានជីវិត ត្រូវមានញាតិមិត្តល្បួងគៃបន្លំ បង្ករឿងក្លែងសេចក្ដី បណ្ដាលឱ្យមានហេតុឈ្លោះទាស់កើតជាអង្គការប្ដឹងផ្ដល់រវាងគ្នាឯង ដើម្បីសម្រេចបំណងធាតុឱ្យឯងធ្លាក់ខ្លួនចុះទៅក្នុងរណ្ដៅមហន្ត រាយ ។

ចំពោះភាពអាសន្ន ៖ ការមួលបង្កាច់ផ្សេងៗ ចោទចាប់ថ្នាក់ដោយអាការៈបំផ្លើសខុសពីការពិត ប្រសិនបើកើតមានដល់លោកអ្នកនាង មានមកពីមនុស្សស្និទ្ធស្នាលគ្នា ឬសាច់សាលោហិតញាតិពន្ធ ឬក៏ញាតិសាខាក៏សឹងមាន ។

ក្នុងខែមិថុនា និង កក្កដា ខែ២នេះ មានសត្រូវនៅជុំវិញខ្លួញថាបើប្រយ័ត្នមិនជិតដល់ទេ ត្រូវទទួលរងគ្រោះអាក្រក់ដល់អាត្មាមិនខាន ហេតុនេះគួរតាំងចិត្តអត់ធន់កុំបំពារបំពានតាមទំនើងចិត្តឡើយ ទោះកិច្ចការនោះមានសភាពបែបណាក៏ដោយ ជាពិសេសមនុស្សទុយិសវាំឆ្លៀតឱកាសលៃសកហេតុឥតឈប់ឈរក្នុងបំណងដណ្ដើមយកភោគទ្រព្យ សិរី យសនិងអំណាចជាកម្មសិទ្ធិផ្ទាល់ បើដឹងហើយមិនគួរឱ្យទេសកាលយ៉ាងនេះបង្កបង្កើតឡើងបាន គប្បីតាំងមានៈឱ្យនឹងនចំពោះកិច្ចការទូទៅ គប្បីប្រព្រឹត្តខ្លួនឱ្យបានប្រក្រតីទៅក្នុងអំពើល្អ និងគប្បីលះបង់អំពើណាដែលពិចារណាទៅឃើញថាមានសង្ស័យមិនអស់មិនហើយ ។

ក្នុងខែសីហា និង កញ្ញា ២ខែនេះ លោកអ្នកនាងបានធូរស្រាលច្រើនអំពីសេចក្ដីអាប់អួរមួរហ្មង រឿងហេតុដែលមានខ្លួនពីពេលមុន ការក្ដៅក្រហាយ សេចក្ដីទុក្ខលំបាកដែលជាបញ្ហាចោទឡើងចំពោះអាត្មា ពេលនេះត្រូវបានដោះស្រាយ រួចស្រឡះមិនគ្រាន់តែប៉ុណ្ណោះ បានជោគជ័យយ៉ាងធំសម្រាប់ពេលវេលានេះ ។

ប្រសិនបើកើតហេតុក្ដីក្ដាំ ត្រូវបានជ័យជំនះលើបច្ចាមិត្តជាស្ថាពរ បើមានការចោទមួលកាច់ ទោះជាប្រការដូច ម្ដេចក៏ដោយក៏មិនបណ្ដាលជាហេតុរំខានបាន មុខតែរម្ងាប់ទៅវិញជាប្រក្រត្យ ។

ចំពោះភោគផល ៖ ការដែលលោកអ្នកនាងប្រព្រឹត្តនិងព្យាយាមយ៉ាងណាៗ មានតែសេចក្ដីសម្រេចបានផលល្អហើយបរិបូរណ៍ជាពិសេស ។

សេចក្ដីបំណងដែលមានគោលដៅចំពោះ សុទ្ធតែមិនមានឧបសគ្គរារាំងបានឡើយ បើទោះជាការនោះមានការធ្ងន់ឬធំហួសវិស័យក៏ដោយ ឱ្យតែការនោះមានលក្ខណៈស្របនឹងវត្ថុធាតុដែលនៅក្បែកកិតនិងអាត្មា ។

ក្នុងខែតុលា និងវិច្ឆិកា ខែទាំង២នេះ មានប្រសិទ្ធភាពណាស់ដល់លោកអ្នកនាងដែលមានអាយុគ្រប់ប៉ុណ្ណោះ ជាការគួរតែសង្ឃឹមទុកដោយរីករាយចុះ ។

ចំពោះកិច្ចការ ៖ បើមានចិត្តគោលទៅលើការងារប្រចាំពេល ដូចជាការកសិករជាដើម ពេលនេះនឹងនាំមកនូវផលយ៉ាងសំបូរហូរហៀរ សូម្បីការនោះស្ដួចស្ដើងក៏ដោយ ជាការពិតត្រូវបានលាភផលយ៉ាងត្រជាក់ចិត្តសឹងតែហួសពីសេចក្ដីប្រព្រឹត្តទៀតផង ។

ម្យ៉ាងទៀតត្រូវបានរួចផុតពីមហន្តរាយដែលជាការនាំឱ្យធ្លាក់ចិត្តអស់មានៈផុតសង្ឃឹម ដោយមានមនុស្សមានភេទផ្ទុយគ្នាជួយឈឺឆ្អាលផ្ដល់ផលប្រយោជន៍រឿយៗ ។

ចំពោះកិត្តិយស : មានសូរស័ព្ទល្បីសព្វទិសទីជិតឆ្ងាយ មានគេកោតសរសើរសឹងតែមិនដាច់ពីមាត់ បានសិរីយស យ៉ាងថ្លៃថ្នូរសឹងតែប្រដូចមិនកើត ។

ក្នុងខែធ្នូ និង មករា ខែទាំង២នេះ គប្បីតាំងស្មារតីឱ្យខ្ជាប់ខ្ជួនមិនគួរប្រហែសខ្លួនទេ លោកអ្នកនាងដែលមានជន្មាយុគ្រប់កម្រិតប៉ុណ្ណេះ មុខតែមានហេតុសៅហ្មងជាមន្ទិលដល់សេចក្តីសុខសាន្ត និងធូរទូលាយគ្រប់ប្រការ ។

ចំពោះហេតុការ : មានតែការសម្រេចចិត្តឱ្យលង់ហួសពីសភាពហេតុដែលកើតមានឡើង ដូចជាកាយរងទារុណគួរឱ្យរំភើបចិត្ត មានវិបត្តិរោគចាប់ផ្តើមឡើងនាបាទានិងហត្ថា សេចក្តីធន់ ស៊ូធ្លាក់កម្រិតអស់កម្លាំង សតិបញ្ញាវិលវល់ខ្លាំង មិត្តក្លាយជាសត្រូវ ប្រភេទនៃការសៅហ្មង បណ្តាលមកពីទិសអាគ្នេយ៍ដែលជាការចាំបាច់ គឺអស់សេរីភាព សត្រូវយកជ័យ ជំនះបានរឿងហេតុដូចតទៅនេះ លោកអ្នកនាងគួរតែខំរកមធ្យោបាយកែខៃច្នៃអាត្មាឱ្យបានស្រួល ដើម្បីទុកពេលរង់ចាំទទួលជោគល្អនាខាងមុខ កុំអាលអស់សង្ឃឹម កុំអាលប្រថុយព្រេងវាសនាតាមយថាកម្មនោះ ។

ក្នុងខែកុម្ភៈ និងមីនា ២ខែនេះ បើលោកអ្នកនាងមានប្រាថ្នាធ្វើដំណើរទៅកាន់ទីស្ថាន ដោយមានការជាចាំបាច់ក្តី ឬមានការទាក់ទងមុខរបរការអ្វីក៏ដោយ នោះមុខជាបានចំរើនផលចំណេញកម្រៃយ៉ាងលើសលប់ ពុំនោះសោតត្រូវបានឡើងនាទីកាន់តំណែងធំដែលត្រូវផ្លាស់ទីកន្លែងដោយទៅឈរនៅតំបន់ស្ថានឆ្ងាយ ហើយបានសំបូរសប្បាយ សុខសាន្តជា និរន្តន៍ ។

ចំពោះផលប្រយោជន៍ : លាភសក្ការៈដែលបម្រុងនឹងកើតមានក្នុងទេសកាលនេះទាក់ទងនឹងទីឆ្ងាយ ប្លែកភូមិ ប្លែកស្រុកតាមពិតប្រសិនបើឱកាសហុចឱ្យ បានប្រតិបត្តិការ ចេញប្រកបកិច្ចការទៅកាន់បរទេសនោះជាជោគជ័យធំសម្រាប់នាទីខែនេះផ្តលនៅ ឯកផលយ៉ាងសម្បើម ។ ពេលនេះសូមយល់ថា សភាវៈទាំងពួងដែលជាការចំរើនរុងរោចន៍លោកអ្នកនាងត្រូវបានជាកម្មសិទ្ធិ ត្រូវប្រាស្រ័យនឹងរឿងហេតុធ្វើដំណើរទៅកាន់ទីឆ្ងាយដាច់ស្រយាល ។

ម្យ៉ាងទៀតបើមានការឈឺថ្កាត់ពុំជា ច្រើនមានជំងឺឈឺជើង ឬដៃ អស់កម្លាំង ស៊ីបាយចំណីមិនបាន បើរៀបចំសែនរំដោះជំងឺចូលធ្វើពែ៨រូត កន្ទោង៥ បាយស ក្រហមញាំភ្លាសាររអាំង ព្រមទាំងបង្អែមដាក់កន្ទោង ប៉ុនរូបស្តេចកាន់ព្រះខ័ន១ រូបបិសាច៣នាក់ រូបស្នងខ្លួនអ្នកជំងឺ១ ដាក់ក្នុងពែនាំយកទៅទុកនាទិសអាគ្នេយ៍ នឹងបានជាសះស្បើយ ។

.............................................................

## រូបភាពទំព័រ (១៣២)

ប្រុសអាយុបាន ១៩,២៧,៣៥,៤៣,៥១ និង ៥៩ ឆ្នាំ

ស្រីអាយុបាន ១៥,២៣,៣១,៣៩,៤៧ និង ៥៥ ឆ្នាំ ។

លោកអ្នកនាងមានអាយុប៉ុណ្ណេះ សឹងមានព្រឹត្តិការណ៍ប្រចាំអាយុរៀងតាមលំដាប់ខែដូចតទៅនេះ :

ក្នុងខែមេសា និងឧសភា ២ខែនេះ សឹងបានសេចក្តីសុខ មានលាភផលច្រើនដោយសារគុណវិជ្ជាផ្សេងៗ បើចេះដឹងអ្វីដែលជាទីនិយមចំណេះនោះនាំមកនូវលាភសក្ការៈ ឬបានទទួលកិត្តិយស កិត្តិគុណតាមសមគួរដល់សមត្ថភាព និងទំហំកិច្ច ការនោះជាពិសេសត្រូវបានសម្រេចនូវគុណវិជ្ជាយ៉ាងប្រសើរមែនពិត ។

ចំពោះសេចក្ដីព្យាយាម : បើលោកអ្នកនាងនៅក្នុងការសិក្សា ពេលនេះត្រូវបានទទួលលទ្ធផលជាទីពេញចិត្ត ដូចជាប្រឡងជាប់ជាស្ថាពរ ប្រឡងចូលធ្វើការជាប់បានធ្វើការ ឬចូលសិក្សាក្នុងថ្នាក់ខ្ពស់ ការព្យាយាមដែលលោកអ្នកនាងបានបំពេញទាំងប៉ុន្មាន សឹងបានសម្រេចផលល្អតាមជាន់ថ្នាក់ ។

ចំពោះហេតុការណ៍ : បើលោកអ្នកនាងបានប្រព្រឹត្ត ឬប្រតិបត្តិយ៉ាងណា យ៉ាងនោះ សឹងបានសម្រេចឥតមានអ្វីមកជំទាស់ជំទែងបាន សភាពការណ៍ដែលពិតជាក់ស្ដែងជាងគេ គឺផ្លូវស្វែងរក ឬបំពេញវិជ្ជាសាស្ត្រ ។

ចំពោះសេចក្ដីស្នេហា : ពេលនេះជាឱកាសសមគួរ លោកអ្នកនាងខំស្រវាស្រទេញរកគូគ្រង ឬគួរទុកដាក់រៀបចំផ្សំផ្គុំឱ្យបានទាន់ពេលវេលានេះនៅគួសម្បស ព្រោះគូព្រេងដែលអាចផ្ញើភ័ព្វវាសនាលើគ្នាបាន ស្ថិតនៅទិសទក្សិណ ត្រូវបានជួបភក្រ្តគ្នារឿយៗដែរ ថាបើបានសម្រេចនឹងគ្នារួចស្រេចទៅ ប្រាកដជាបានសុខក្សេមក្សាន្ត មានទ្រព្យធនល្មមសង្ឃឹមបានរក្សាគ្នាដល់ចាស់ព្រឹទ្ធចាស់ព្រេង ប្រកបការងារបានកើតកាលវាលគុម្ព បានសន្តតិពង្សដល់អវសាន ។

ក្នុងខែមិថុនា និង កក្កដា ២ខែនេះ លោកអ្នកនាងមុខតែបានដល់នូវគោលដៅពិតហើយ ទោះបីយ៉ាងណាក៏ដោយតាមហេតុពិត លោកអ្នកនាងត្រូវបានចេញទៅកាន់បរទេសក្នុងករណីបន្តវិជ្ជា ឬបេសកកម្ម ការដែលចេញទៅអាស្រ័យ ហេតុនាយ ឬលោកជាធំ មានមនសិកាសន្ដោសប្រោសប្រាណដល់ខ្លួន ។

ចំពោះសេចក្ដីសម្រេច : វិជ្ជាក្នុងខ្លួនរបស់លោកអ្នកនាងចាប់បញ្ចេញពន្លឺរស្មីត្រចះ ជាទីគួរអ្នកផងកោតសរសើរ និងលើកតម្កើង និងបានរីកសាយផ្លាយបរិវេណវែងឆ្ងាយនាយបញ្ជោការចូលចិត្តរាប់អាន ផ្ទុកផ្ដាក់កិច្ចការដែលមានសារៈសំខាន់ឱ្យកាន់កាប់ផ្ទាល់ខ្លួន ជាពិសេសឱ្យទទួលឋានៈជាអ្នកទទួលនាទីទ្វេភាគ ក្នុងភារៈការទ្បេងផង ។

ចំពោះសេចក្ដីរុងរឿង : ការដែលបានធ្វើ ឬដែលបានគ្រោងទុក ទោះជាមានការតឹងចង្អៀតខ្លះក៏ដោយ ក៏គង់ធ្វើដំណើរទៅបាន បើទៅដោយត្រង់ៗមិនបាន ក៏ត្រូវដំណើរតាមផ្លូវអមគង់នឹងសម្រេចជាពិសេសបានរុងរឿង សំបូរសេចក្ដីរាប់អានមេត្រីច្រើន ទោះក្នុងវង់សង្គមការក៏ដូចជាក្រៅសង្គមដែរ ។

ក្នុងខែសីហា និង កញ្ញា ២ខែនេះ លោកអ្នកនាងដែលមានជន្មាយុកម្រិតតែប៉ុណ្ណេះ ច្រើនមានការរំខានផ្សេងៗច្រើនទៅដោយសត្រូវ គឺមិត្តមានក្លាយជាសត្រូវខ្លះផង ថាបើមានសេចក្ដីធ្វេសប្រហែសមុខតែសត្រូវប៉ងប្រទុស្តរាយវាសម្រេចដូចបំណងវាបាន ក្នុងពេលនេះមិនគួរធ្វើដំណើរទៅឆ្ងាយទៅកាន់ទិសខាងត្បូងទេ ។

ចំពោះហេតុការណ៍ : សត្រូវចាស់ចងសេចក្ដីព្យាបាទយ៉ាងក្សៀវក្លា ហើយព្យាបាទនោះមានលក្ខណៈជារឿងសា ហ័សបើពុំនោះត្រូវប្រយ័ត្នប្រាណ កុំគប្បីកាន់ ឬទុកគ្រឿងសាហ័សដោយពាមងាយ កុំគប្បីជន្លិបជន្លួរលេងប្រលែងដោយ គ្រឿងទាំងនោះ បើមិនជាការចាំបាច់ មិនគួរដើរលេងកំសាន្តនាពេលយប់ឡើយ ។

ចំពោះកិច្ចការ : ការប្រក្រតីច្រើនមានគ្រឿងស្មោកស្មានម្ដងៗ ខំធ្វើដល់គេ គេមិនធ្វើល្អសងវិញឡើយ មុខការខំព្យាយាមប្រតិបត្តិយ៉ាងណាក៏ដោយ មានគេចាំថ្កោលមួលបង្កាច់មិនសមហេតុផល មានសេចក្ដីធុញទ្រាន់សោយចំណង់ក្នុង មុខការគំនិតនឹកចង់តែដូរផ្លាស់មុខការនឹងនាទី ជាពិសេសមនុស្សរួមការត្រូវជើងគ្នាមានការបកស្រាយ ពោលអាក្រក់ ផ្សេងៗឥតសំចៃមាត់ ។

ចំពោះភាពអាសន្ន : ជាថៃ្ងដន្យមានហេតុកើតឡើង ព្រោះយកអាសារញាតិមិត្ត អ្នកទាំងនោះបញ្ចេញភស្តុតាងឱ្យដល់គូបដិបក្ខចាស់ ដោយចំពោះសេចក្តីប្រមាថមានទំហំធំលើសលប់ តែអាចគេចជៀសផុតបានដោយដឹងខ្លួន ហើយពិចារណាទៀតផង ។

រឿងនេះសូមលោកអ្នកនាងប្រយ័ត្នឱ្យបានមុខមាំចុះ គួរប្រើសេចក្តីពិនិត្យពិចារណាឱ្យបានញឹកញាប់បន្តិច ។

ក្នុងខែតុលា និងវិច្ឆិកា ២ខែនេះ លោកអ្នកនាងមុខជាមានព្រួយរំខានកើតឡើងរឿយៗ សេចក្តីឈឺចាប់ក៏មាន ដោយហួរហែការងារដែលជាចាំបាច់ ក៏ត្រូវបានសេចក្តីកង្វល់មកស្ទាក់បង្អាក់មិនឱ្យសម្រេចបាន មុខងារដែលមានសង្ឃឹម យ៉ាងប្រាកដប្រជាក៏ត្រឡប់ជាចេញមិនរួច ដោយមានគេចាំដេញជើងក្នុងសភាពដណ្តើមយកកន្លែង ឬនាទីផ្តាច់មុខ ។

ក្នុងបន្ទុកគ្រួសារ : មានតែសេចក្តីរង្គាល និងខ្វះខាតថវិកាគ្រួសារប្រាក់ប្រចាំគ្រួសារ ត្រូវការចេញចាយហួសពីការប៉ុនលៃយ៉ាងត្រឹមត្រូវ សេចក្តីកង្វល់ពីគ្រួសារមានមិនចេះអស់មិនចេះហើយ កង្វល់មួយកន្លងផុតទៅ កង្វល់ថ្មីមួយចូលមក ទៀតចង់អស់សមត្ថភាពនិងកែខៃ ។

ចំពោះសេចក្តីរំខាន : ការដែលជាបញ្ហាស្មុគស្មាញចោទចំពោះជាងគេ គឺវិបត្តិរោគ ដូចជាថ្លង់ គ្រេច ជំពប់ ពារ ប៉ះ កោសមុតតែបន្តិចបន្តួចក៏ប្រែក្លាយទៅជារាលដាលឱ្យកើតចុកចាប់ឈឺផ្សា បណ្តាលឱ្យរំខានខកអស់កិច្ចការ ព្រមទាំងត្រូវការចាយប្រាក់ទិញដូរថ្នាំប្រចាំតែជំងឺនោះ នេះហើយដែលសុភាពសិតបុរាណពោលថា "ប្រាក់ក៏បង់ ថង់ក៏ដាច" ។

ចំពោះគុណវិបត្តិ : សតិបញ្ញាច្រើនវង្វេងភាន់ឡប់សឹងតែរកគិតអ្វីមិនលេច កិច្ចការក្តី ទ្រព្យរបស់ក្តី ចេះតែច្រឡំជ្រួសមុខក្រោយ ចិត្តអណ្តែតអណ្តូង សំបូរការមួរម៉ៅ ជួនកាលភ័យខ្លាចទទេឥតហេតុផល បើបានដើរចេញទៅក្រៅភូមិ ឋានទើបរយាលសេចក្តី លុបសៅម៉ៅមួរ ការយល់ខុសប្រកាន់យកជាត្រូវ ចចេសរឹងរូសមិនមានសេចក្តីខ្មាសអៀន ។

អាការដូចពោងខាងលើនេះ លោកអ្នកនាងសូមជ្រាបថា បើគ្មានសេចក្តីប្រុងប្រយ័ត្នទុកជាមុនទេ ពេលនេះត្រូវរង្គោះរង្គើយ៉ាងសម្បើម តែបើបានតាំងស្មារតីពង្រឹងមានះឱ្យរឹងក្លា តទប់នឹងគ្រោះកំណាចយ៉ាងនេះទើបបានរីអាត្មារួចពីគំនរទោសទណ្ឌបាន ជាពិសេសមិនគួរទៅកាន់ទីឆ្ងាយដាច់ស្រយាលនាទិសទក្សិណឡើយ ។

ក្នុងខែធ្នូ និង មករា ២ខែនេះ លោកអ្នកនាងមានសេចក្តីរីករាយចិត្តច្រើនហើយ លាភផលក៏រកបានដូចបំណងញាតិមិត្តក៏មានចិត្តភក្តីរាប់រកច្រើន សតិបញ្ញាក៏ឆ្លាត រហ័សរហួនល្អ ចិត្តអធ្យាស្រ័យក៏បាត់ធុញថប់ ប្រែជាមានការកក់ក្តៅឃើញខុសត្រូវតាមយថាការ ។

ចំពោះសេចក្តីចំរើន : នាយចៅហ្វាយយល់ឃើញហេតុពិតពីកិច្ចការរបស់អាត្មា ជួយឧបត្ថម្ភចង្អុលប្រាប់ផ្លូវឱ្យដំណើរទៅកាន់ផ្លូវប្រយោជន៍ ពុំនោះមានគេជួយផ្តល់ដើមទុនឱ្យប្រកបការរបរដែលគួរដល់សេចក្តីប្រព្រឹត្តរបស់អាត្មា ធ្វើការប្រកបទៅដោយលាភផល ស័ក្តិសិទ្ធិតាមរបៀបគិតត្រូវប្រកបការទៅមានគេជួយឱ្យយោបល់ល្អ បានសុខ លាភអស្ចារ្យ

ចំពោះសេចក្តីសុខ : ពេលនេះជាពេលអភ័យរបស់លោកអ្នកនាងហើយ គឺថាសេចក្តីទុក្ខព្រួយ ការបៀតបៀនចាក់រុកថ្កោលទោស និន្ទា រិះគន់ និងសេចក្តីធុញទ្រាន់តុះស្អុះស្អាប់ទាំងអស់នេះ ទោះជាវត្ថុធាតុទាំងនេះមានចាស់យូរមកក្តី ឬថាមានឡើងថ្មីៗក្តី ក្នុងខណៈនេះជាអហោសិកម្មលែងផ្តល់ទោសបានទៀតហើយ មានតែសេចក្តីចំរើន រុងរឿង សម្បូរ សប្បាយថ្ងៃណាក៏ដូចជាថ្ងៃណា សឹងមានបានតាមសមគួរដល់សេចក្តីប្រព្រឹត្តិ និងវត្ថុចោមរោមជាជុំវិញខ្លួនរបស់អស់លោក អ្នកនាង ។

ក្នុងខែកុម្ភៈ និង មីនា ២ខែនេះ អស់លោកអ្នកនាងមុខតែបានជួបប្រទះនឹងសុភមង្គល សុភវិនិច្ឆ័យរំភើបចិត្ត ផលការដែលបង្កើតឡើងជាផលល្អមានប្រចាំអាយុ ដូចជាសេចក្ដីក្សេមដែលជាប់ទាក់ទងនឹងលាភយ៉ាងឯក"ឯកលាភ" បើទេសកាលនេះមានព្រមជាមួយឫក្សជតាផង សភាវៈយ៉ាងនេះនឹងបានរង្វាន់ត្រូវឆ្នោតជាតិ(រង្វាន់ធំ)ជាមិនខាន ពុំនោះរើសបាននូវវត្ថុមានតម្លៃដែលគេជ្រុះ ឬភ្លេច ។

នាទីនេះត្រូវបានលាភលឿង និងលាភស ប្រាកដជាងលាភនានា សេចក្ដីសុខកាយសប្បាយចិត្តក្នុងពេលនេះចាត់ទុកជា"អត្ថិសុខ" គឺសុខកើតឡើងតាមរយៈការដៅ ឬបំណង ឧបសគ្គនានាមិនបានមកជិត ឬជិតដល់ឡើយ ក្នុងពេលជា មួយគ្នានេះទឹកចិត្តផូរផង់គំនិតគិតត្រូវឬតម្រិះត្រូវ សតិចងចាំល្អ បញ្ញាភ្លឺស្វាង សភាវធម៌ទាំងអស់នេះសឹងកើតមានក្នុងសន្ដានរបស់លោកអ្នកនាងជានិច្ចនិរន្តរ៍ ជាពិសេសខាងគតិធម៌ ក្នុងរយៈពេលនេះបើមានសន្ដានទោទន់ទៅខាងផ្លូវសីលធម៌ ដូចជាការចូលខ្លួនទៅអប់រំក្នុងគន្លងសាសនធម៌(វិបស្សនៈកម្មដ្ឋាន) មុខតែបានសម្រេចនូវបិតីបាមោជ្ជយ៉ាងធូរងាយ ជាការចាំបាច់មានអធ្យាស្រ័យទន់ភ្លន់ ប្រាសចាកគ្រឿងសៅហ្មងទាំងពួង ។

ប្រសិនបើមានជំងឺវិបត្តិបង្កបង្កើតឡើង សូមប្រញាប់ធ្វើពែ៨រួត កន្ទោង៦ បាយសក្រហមញាំភ្លាសារអាំងដាក់ កន្ទោងប៉ុនជារូបស្ដេច១ យក្ខ១ បិសាច៤នាក់ រូបតំណាងមនុស្សជំងឺ១ សែនរួចបញ្ជូនទៅទុកខាងទិសទក្សិណ នឹងបានជាសះស្បើយជាប្រាកដ ។

.............................................